# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0105**

## សម្ភាសន៍ជាមួយឈ្មោះ ចាប សៅ ភេទប្រុស អាយុ៥០ឆ្នាំ

មុខងារខ្មែរក្រហមៈ កងចល័ត

មុខងារបច្ចុប្បន្នៈ ជាចៅអធិការវត្តឧត្តមសុធារាមប្រាសាទធាតុ

ស្រុកកំណើតនៅភូមិស្តុកឃ្លោក ឃុំព្រះម្លូរ ស្រុកបាកាន ខេត្តពោធិ៍សាត់

សព្វថ្ងៃរស់នៅភូមិភាសត្បូង ឃុំសារង្គ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០១:១៤:១៧

៣៤ទំព័រ

ដានី : ព្រះអង្គអញ្ជើញជំបូនខ្ញុំករុណាចង់ស្គាល់ព្រះនាមព្រះអង្គ?

សៅ : ចាប សៅ ។

ដានី : សព្វថ្ងៃមានព្រះជន្មប៉ុន្មានហើយព្រះអង្គ?

សៅ : ៥០ ។

ដានី : ព្រះអង្គសព្វថ្ងៃជាចៅអធិការវត្ត?

សៅ : ជាចៅអធិការ ។

ដានី : វត្តនេះគេហៅវត្ត?

សៅ : វត្តឧត្តមសុធារាមប្រាសាទធាតុ ។

ដានី : វត្តឧត្តមសុធារាមប្រាសាទធាតុ នៅក្នុងភូមិឃុំអ្វីដែរហ្នឹង?

សៅ : ភូមិភាសត្បូង ឃុំសារង្គ ។

ដានី : ស្រុកស្វាយចេក?

សៅ : បាទ!ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

ដានី : ព្រះអង្គស្រុកកំណើតព្រះអង្គនៅណាដែរ?

សៅ : នៅភូមិស្តុកឃ្លោក ឃុំព្រះម្លូរ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

ដានី : ព្រះអង្គបួសប៉ុន្មានឆ្នាំហើយ តាំងពីឆ្នាំណា?

សៅ : បួសឆ្នាំ២០០៥ ។

ដានី : អ៊ើ!ញោមប្រុសឈ្មោះអីដែរ?

សៅ ៖ ចាប ហន់ ស្លាប់ហើយ ។

ដានី ៖ ស្លាប់ឆ្នាំណាដែរព្រះអង្គ?

សៅ ៖ ស្លាប់ឆ្នាំដូចជា២០០២ហើយ ។

ដានី ៖ ដោយសារជំងឺ?

សៅ ៖ ចាស់ជរាពាធ ។

ដានី ៖ ញោមស្រី?

សៅ ៖ នាក់ វ៉ា ស្លាប់នៅឆ្នាំ១៩៧៧ ។

ដានី ៖ ស្លាប់ដោយសារមូលហេតុអីកាលហ្នឹងជំនាន់ពាឆ្នាំ?

សៅ ៖ កាលហ្នឹងនៅជំនាន់៣ឆ្នាំហ្នឹង មរ៉ ម៉ោកងចល័តម៉ោដែរហ្នឹងក៏ដោយសាររឿងអត់ថ្នាំព្យាបាល រឿងខ្វះអាហារហ្នឹង ។

ដានី ៖ ខ្វះអាហារ?

សៅ ៖ ហ្នឹងហើយ ។

ដានី ៖ ព្រះអង្គមានបងប្អូនប៉ុន្មាននាក់ហើយ?

សៅ ៖ អាត្មាមានបងប្អូន៥នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សៅ ៖ ស្រី៣ ប្រុស២ ។

ដានី ៖ ព្រះអង្គកូនទីប៉ុន្មាន?

សៅ ៖ អាត្មាទី៤ ។

ដានី ៖ ព្រះអង្គកាលពីក្មេងៗ ព្រះអង្គធ្លាប់បានរៀនសូត្រដល់ថ្នាក់ណាដែរ?

សៅ ៖ ដល់ថ្នាក់ទី៨ចាស់ ។

ដានី ៖ នៅសាលាណា?

សៅ ៖ នៅសាលាបឋមសិក្សាស្តុកឃ្លោក ។

ដានី ៖ ព្រះអង្គឈប់រៀនឆ្នាំណា?

សៅ ៖ ឈប់រៀនឆ្នាំដូចជា៧០ប៉ុន្មានទេ ។

ដានី ៖ ឆ្នាំ៧០រដ្ឋប្រហារ ។

សៅ ៖ ឆ្នាំ៧០រដ្ឋប្រហារហ្នឹងហើយហ្នឹងក៏នៅរៀនបាន១ឆ្នាំ២ទៀត ។

ដានី ៖ករុណា!

សៅ : បានខ្មែរក្រហមចូលស្រុកហ្នឹង បានអស់សាលា ៧២-៧១ហ្នឹង ។

ដានី : ពេលដែលខ្មែរក្រហមចូលស្រុកទៅក៏អស់សាលា?

សៅ : ក៏បាក់បែក ។

ដានី : ពេលឈប់ហ្នឹងព្រះអង្គទៅណាទៀតទៅ?

សៅ : ហើយជាមួយក្រុមគ្រួសារហ្នឹងម៉ោនៅយើងប៉ោយប៉ែត ។

ដានី : គ្រួសារទាំងអស់គ្នា?

សៅ : គ្រួសារដោយឡែក ហើយអ្នកនៅលីវ ដូចជាអាត្មា ប្អូនអាត្មា ហើយនឹង ក្រៅពីហ្នឹង គេបាត់គ្រួសារអស់ហើយ ក៏បែកៗគ្នាទៅ ។

ដានី : អញ្ចឹងតាំងពីឆ្នាំ៧២ម៉ោផ្លាស់មកនៅ ប៉ោយប៉ែត?

សៅ : ពរ ។

ដានី : ម៉េចបានកាលពីជំនាន់ហ្នឹងផ្លាស់ពីស្រុកកំណើតមកនៅប៉ោយប៉ែត?

សៅ : ឪពុកម្តាយហ្នឹងគាត់ដូចថា វានៅក្នុងស្រុកទៅវាមានដូចថា ពួកព្រៃពួកស្រុកអីហ្នឹងវល់វិកទៅ គាត់ក៏ភៀសខ្លួនចេញពីភូមិកំណើត ដូចថាស្រុកវាកើតសង្រ្គាមអញ្ចឹង ។

ដានី : គាត់ភៀសខ្លួន?

សៅ : ភៀស ។

ដានី : គាត់ភៀសខ្លួនម៉ោទាំងអស់ ។

សៅ : ទាំងអស់ នៅ៤នាក់នេះ ហើយឯបងស្រីៗទាំង៣ហ្នឹងគាត់មានគ្រួសារដែរ គាត់ក៏រស់តាមដំណើររបស់គាត់ គាត់អត់បាននៅរស់ជុំគ្នាទេ ។

ដានី : ដល់អញ្ចឹងទៅ ពេលដែលម៉ោរស់នៅប៉ោយប៉ែត យ៉ាងម៉េចទៅគ្រួសាររបស់ព្រះ អង្គ?

សៅ : ម៉ោឪពុកហ្នឹងក៏ចាំឃ្វាំងស្ករស ចាំឃ្វាំងអើស្ករពីដើមគេហៅ ប៉ះស៊ីវ៉ុងស្ករស ។

ដានី : ស្ករសម៉ោពីខាង?

សៅ : ខាងម៉ោពីសៀម ។

ដានី : ខាងម៉ោពីសៀម កាលហ្នឹងខាងរំដោះ ឬក៏ខាង លន់ ណុល?

សៅ : អត់ទេ!ខាង លន់ ណុល ខាងៗហើយ ព្រោះក្រុមៗសុទ្ធតែលន់ ណុល ។

ដានី : ការណា!

សៅ : ព្រោះខាងស្រុកកំណើតហ្នឹង ខ្មែរក្រហមចូលម៉ោហើយ ។

ដានី : ការណា!

សោ ៖ ពរ!

ដានី ៖ ចុះព្រះអគ្គ ហើយប្អូនៗបងប្អូនផ្សេងៗទៀតធ្វើអីទៅ?

សោ ៖ ណែ៎!គាត់ហ្នឹងក៏បងស្រីទី២ទី៣ហ្នឹងក៏ម៉ោប៉ោយប៉ែតដែរ ប៉ុនតែថាផ្ទះផ្សេងគ្នា រកស៊ីតាមកម្លាំងគាត់ទៅ ។

ដានី ៖ កាលណា!ហើយព្រះអគ្គកាលហ្នឹងធ្វើអីទៅ?

សោ ៖ នៅស្ងៀរៗដែរ ជួយការងារឪពុកហ្នឹងដែរ ឃ្វាំងៗហ្នឹងរបស់ថៅកែ ឃ្វាំងរបស់នាយ ទុនឃ្វាំងស្តុរស ដាក់ជំនួញ ។

ដានី ៖ រហូតជួយការងារឪពុកដល់ឆ្នាំណាទៅ បានព្រះអគ្គចេញ?

សោ ៖ ដល់៧៥ ខែមេសាហ្នឹង ត្រូវជម្លៀសចេញពីប៉ោយប៉ែត កាលហ្នឹងខាងខ្មែរក្រហមហ្នឹងបានក្តាប់ទូទាំងប្រទេសហើយណាស់! ។

ដានី ៖ កាណា!

សោ ៖ ហ្នឹងហើយ ក្រោយ១៧មេសា មិនប៉ុន្មានថ្ងៃហ្នឹងក៏ត្រូវជម្លៀសចេញពីទីប្រជុំប៉ោយប៉ែតហ្នឹង ក្រុមគ្រួសារអាត្មា អាត្មាផ្ទាល់ហ្នឹងទៅនៅជំបូកក្នុង ឃុំល្វា ស្រុកមង្គលបុរី ។

ដានី ៖ កាលា!

សោ ៖ ពរ!ហើយក៏ជម្លៀសទៅហ្នឹង ។

ដានី ៖ យ៉ាងម៉េចទៀតទៅ?

សោ ៖ បន្ទាប់ម៉ោហ្នឹងប៉ុន្មានជា៧៥ ប្រហែលជាខែ៧ អាត្មាហ្នឹងត្រូវគេប្រមូលយុវជនអាត្មាហ្នឹងក៏ជាប់ជាយុវជននឹង គេទៅឲ្យទៅធ្វើកងចល័ត កងចល័តនៅយើងកូនដំរី គេហៅថានិមិត្ត ពរ! ។

ដានី ៖ កាណា!យ៉ាងម៉េចទៀតទៅ?

សោ ៖ រហូតដល់យើង មានសង្គ្រាម ដែលថាកម្លាំងរំដោះចូលម៉ោហ្នឹង ១៩៧៩ហ្នឹង ពេលហ្នឹងនៅកំពុងច្រូតនៅឡើយទេ កងចល័តហ្នឹង កំពុងតែច្រូតកាត់ហ្នឹងអត់ដឹងសភាពការណ៍អីទេ ព្រោះសម័យ៣ឆ្នាំហ្នឹងផ្តាច់ប្រពន្ធ័ពត៏មានអី អត់មានដឹងអីទេណា៎ អត់មាន វិទ្យុ អត់មានរ៉ាត់យូរអីបានទទួលពត៏មានអីយ៉ាងណាទេ សូម្បីតែកម្លាំងខាងក្រៅឬក៏រំដោះហ្នឹងម៉ោដល់សិរីសោភ័ណហើយហ្នឹង ពួកអាត្មាដែលជាកងចល័តហ្នឹងអត់ដឹងអីផងរាប់ពាន់ចូលជិតម៉ឺននាក់ក្នុងម៉ាចនោះហ្នឹង អត់មានដឹងអីទេ ស្រាប់តែឡាន ឃើញឡានខាងភ្នំពេញ មានរថភ្លើងក្នុងកំឡុងមុនដែលកម្លាំងរំដោះចូលទៅដល់យើងកូនដំរីនិមិត្ត ហ្នឹង

ឃើញមានដឹកពួកភ្ញៀវពួកទូតអីទៅថៃ ជាខ្សែៗដែរ ប៉ុន្តែថាមិនបានចាប់ អារម្មណ៍អីទេ ព្រោះមិនបានដឹងអីទេ ហើយដល់ថ្ងៃនោះ អាត្មាចាំក្នុងមិនមែនជាខែ ១ទេប្រហែលតាមមើល បើខែ១ក៏ចុងខែដែរ ព្រោះកម្លាំងរំដោះហ្នឹងម៉ោដល់យើង និមិត្តកូនដីរហ្នឹង ហើយស្រាប់តែដល់ក៏ដូងផាងទៅក៏ អាត្មាត្រូវខាង គេហៅថាយោធា យោធាប្រចាំមូលដ្ឋានហ្នឹង យោធាខ្មែរក្រហមហ្នឹងណា ក៏បានប្រមូលកងចល័តរួមគ្នា ខាងភ្នំពេញម៉ោ ខាងភ្នំពេញហ្នឹង អាត្មាចាំឈ្មោះបានមានឈ្មោះ លោក សរ ហុង ៗ

ដានី : សូរ ហុង?

សៅ : ហ្នឹងហើយ សូរ ហុង ៗហ្នឹងហើយមានលោកពេជ្រ បូរ៉េត មានអីហ្នឹងដែលស្គាល់គាត់ណាស់ហើយនឹងលោកនេះមួយទៀត ពូ ខុនៗឈ្មោះគាត់មិនអីទេ គាត់ម៉ោពីភ្នំពេញម៉ោ ម៉ោប្រមូលកងចល័តហ្នឹង ប្រមូលបក្ខរបំពាក់អាវុធ ហើយអាវុធហ្នឹងបំពាក់ទាំងអស់ហ្នឹង ប៉ុន្តែកាំភ្លើងកាលហ្នឹងគេថា MCរាកៃនោះអត់មានបង់ទេ ហ្នឹងហើយអាហ្នឹងបក្ខលក្ខណៈហ្នឹង គឺចេញផ្លូវជាតិលេខ៥យើងទៅ ទៅខាងនោះអូរគេហៅថាម៉ាជួរខែដន ម៉ាជួរគោកធំ ពាំងមួង អូរឡាំមជិក ខ្សែបន្ទាត់ហ្នឹងកម្លាំងចល័តទាំងអស់ហ្នឹងត្រូវបំពាក់អាវុធហ្នឹង តែដឹបូងហ្នឹងគឺ ដោយមានកម្លាំងយោធា ម៉ោឆ្នុះៗអញ្ចឹងទៅមួយកងហ្នឹង៣០នាក់អញ្ចឹងទៅមានខាងយោធាហ្នឹងលាយខ្លះ អញ្ចឹងហើយបេះតែវ៉ាយវ៉ាប់នោះ?

ដានី : កាណាៗ!

សៅ : មិនបាច់សួរទេ បេះតែវ៉ាយវ៉ាប់ កន្លែងណាចាំបាន?

ដានី : កាណា!សូមបញ្ជាក់បន្តិចទាក់ទងនឹងព្រះអង្គចាប់ផ្ដើមចូលធ្វើក្នុងកងចល័ត កន្លែងហ្នឹង កន្លែងកងចល័តហ្នឹងការងារគេឲ្យធ្វើស្អីខ្លះទៅ?

សៅ : គឺធ្វើតែស្រែមួយមុខគត់ ស្រែហ្នឹងគឺមានច្រើនសណ្ឋានណាស់ ស្រែហ្នឹងគឺពួកអាត្មាហ្នឹងកងចល័តហ្នឹងគឺកាប់ចបសុទ្ធ តាំងពីអើយម៉ោកាប់តែនឹងដៃសុទ្ធ អ្នកមានគោគេកងគោគេមាន មានកងនង្គ័លគោហ្នឹងគឺសម្រាប់កល់គោហ្នឹងគឺមានម៉ាក្រុម ប៉ុន្តែវាតិចតួចហើយក្រៅពីហ្នឹង ទាំងយុវជនយុវនារីហ្នឹងគឺចបទាំងអស់ ហើយដល់ពេលស្ទូងហើយ ហ្នឹងខែនេះខែទឹកបិទទំនប់បិទអាង ខែប្រាំងបិទភ្លឺ ខែប្រាំងលើកភ្លឺ លើកភ្លឺយកៗម៉ង លើកភ្លឺប្រព័ន្ធបន្ទារឈើត្រង់ហ្នឹង ខែវស្សាកាប់នឹងចប ហើយនឹងបោកនឹងដៃ មានគ្រាក់ទ័រអីមកបញ្ជាន់ហ្នឹងឃើញថាក្នុងតិចតួចណាស់ ដល់ឆ្នាំ៧៧ អីហ្នឹងឃើញមាន

ម៉ាស៊ីនបោកអាឈរកាន់ដៃធ្លាក់បាន២-៣គ្រឿងដែរ ក្រៅពីហ្នឹងបោកដៃសុទ្ធ ថ្ងៃប្រូត យប់បោក ។

ដានី : ព្រះអង្គមានពុទ្ធដីកាថា កាលហ្នឹងមានកងចល័តរាប់ម៉ឺននាក់ហ្នឹង អាហ្នឹង?

សៅ : ក្បែរៗ ។

ដានី : អញ្ចឹងកងចល័តហ្នឹងម៉ោពីណាខ្លះម៉ោ?

សៅ : កងចល័តហ្នឹងគឺទាំងអ្នកជម្លៀសមែនទែនទៅ គឺម៉ាតំបន់៥ គេហៅថាតំបន់នេះគឺចាប់ពីសិរីសោភ័ណនេះ ថ្មពួក ព្រះនេត្រព្រះ គេហៅថាតំបន់៥ ឯមង្គលបុរីយើងទៅដល់ជិតថ្មគោលទៅខាងហ្នឹង គេហៅថាតំបន់៣ ដូច្នេះកម្លាំងហ្នឹង គឺទាំងកម្លាំងជម្លៀសថ្មីទាំងកម្លាំងនៅភូមិ តាមយើងអីនានាហ្នឹងគឺដកយុវជនយុវនារីទៅធ្វើកងយុវជនចល័ត ។

ដានី : អាយុពីចន្លោះប៉ុន្មានដល់ប៉ុន្មាន?

សៅ : អាយុមែនទែនទៅ មានកងកុមារក៏យកដែរ អាយុ១៣-១៤ហ្នឹងកងកុមារ១២អីហ្នឹងគឺកងកុមារហើយ ហើយកងកុមារហ្នឹងមិនបានសម្រាក់អីទេ មិនខុសពីយុវជនអីទេ គ្រាន់តែថាអាណាកាប់ចបបានក៏កាប់ចបទៅ អ្នកណាកាប់ចបមិនបានក៏រើសស្មៅ រើសអីអញ្ចឹងទៅ អត់មានទំនេរ ។

ដានី : ហើយមានគ្នារាប់ម៉ឺននាក់ហ្នឹង មានអ្នកគេគ្រប់គ្រងឈ្មោះអីទៅ?

សៅ : មានកាលហ្នឹង គឺកាលដំបូងឡើយគឺថាឈ្មោះន៉ែ គេហៅថា កាឈឿង ដែលថាអ្នកយើងធ្វើកងចល័តហ្នឹង អ្នកធ្វើកងចល័តហ្នឹងគឺគាត់ហ្នឹងនៅស្រុកកំណើតនៅមង្គលបុរីនេះឯង ។

ដានី : តា ឈឿង?

សៅ : តា ឈឿង ប៉ុន្រក្រោយពីហ្នឹងម៉ោ ប្រហែលជា១ឆ្នាំរគាត់ត្រូវដដកចេញទៅ ដាក់ថាពួកនិរតី គាត់ឈ្មោះគាត់ សុភាព ហ្នឹងហើយ ប្រធានកងចល័តហ្នឹង ភាពៗហ្នឹងប្រុសមិនមែនឯកឧត្តម សុខភាពនេះទេ ឯកឧត្តម សុខភាពនេះគាត់ក៏នៅហ្នឹងដែរ តែគាត់ជួរកងទ័ព ហ្នឹងហើយជួរកងទ័ព គាត់នៅខាងកងទ័ពព្រំដែន នឹងឯភាពមួយទៀតគឺគាត់ភាពដែរ ទាបល្អិត ក្រោយមកទៀតជិតដល់៧៩ហើយ ចុង៧៨ហ្នឹងក៏ដក ភាព ទៅទៀត ម្ដងនេះម៉ោជាមិត្តនារីម្ដងឈ្មោះថាគេហៅថាយាយសួរៗហ្នឹង ក៏អ្នកម៉ោពីកំពតតាកែវហ្នឹងដែរ ។

ដានី : កាណាហើយមួយទៀត កាលដែលធ្វើការកងចល័តហ្នឹងដូចថា ធ្វើការយ៉ាងម៉េចដែរ ដូចថាធ្វើការយ៉ាប់យ៉ឺនដែរឬក៏យ៉ាងម៉េច?

សៅ : គឺ មិនដែលបបរទេ កងចល័តហ្នឹង គឺមួយពេលមួយកប៉ុងអង្ករ ។

ដានី : ម្នាក់១កំប៉ុង?

សៅ : ម្នាក់មួយកំប៉ុងបានព្រឹកល្ងាច ។

ដានី : បាទ!

សៅ : ហើយការដាំបាយហ្នឹងគឺច្នៃប្រឌិតទៅ ច្នៃប្រឌិតថាធ្វើយ៉ាងណាឲ្យស្មើភាព ដាដាក់ចាន ឬក៏ផ្ទិលអីវាស់អង្ករៗតាមកងហ្នឹងគឺដាក់ចំហុយទៅ ព្រោះការពារខ្លាចថាដួសតិចដួស ច្រើនខាងចុងភៅហ្នឹង ឯចុងភៅហ្នឹងគឺមួយកងតូចហ្នឹង ពី៣០-៤០នាក់ហ្នឹងតែមួយទេ ត្រូវដាំត្រូវស្ល ត្រូវតែរែក រែកចំណាយរាប់គីឡូ យកទៅឲ្យអីនៅការដ្ឋាននោះ នៅឆ្ងាយប៉ុណ្ណាក៏ដោយ ហើយខ្សែកហ្នឹងម៉ាវរហ្នឹងគេហៅថាពួកនេសាទហ្នឹងមួយកងវរ សេនាតូច រៀបដាររបៀបវរដែរ រៀបដូចកងទ័ពដែរ ប៉ុន្តែជាកងចល័ត មានកង មានក្រុម ពួក ក្រុម កងតូច កងធំ វរ ហើយវរសេនាធំអីដែរ ។

ដានី : ដល់ពេលចាប់ធ្វើការ ចាប់ធ្វើពីព្រលឹម?

សៅ : ធ្វើម៉ោង៤ត្រូវតែក្រោក ក្រោកទោះបីយ៉ាងណា មិនទាន់មើលផ្លូវឃើញក៏ដោយត្រូវ ត្រូវតែអង្គុយ អង្គុយស្តាប់មេកងធំឬមេកងតូចនឹងណែនាំ ពីគោលនយោបាយ អំពី សភាពការណ៍អីៗហ្នឹងគឺអាស្រ័យស្តាប់បានតែត្រឹមមេកងតូច ឬក៏ពេលអង្គុយតំរង់ជួរ ងងឹតក៏ដោយ យ៉ាងណាក៏ដោយត្រូវតែក្រោក ។

ដានី : ម៉ោ៤ហ្នឹងគេដាស់គ្រប់គ្នា?

សៅ : គ្រប់គ្នាគឺទូទៅម៉ង ក្នុងម៉ាកងចល័តនិមិត្តហ្នឹង ។

ដានី : ដល់ពេលដាស់ទៅ មេកងគេចាប់ផ្តើមណែនាំថាត្រូវ?

សៅ : ហើយចូលជាជួរ ហើយពិនិត្យកម្លាំង អ្នកណាឈឺ បាត់អីប៉ុន្មាន ឈឺហ្នឹងឈឺពិតប្រាកដ ឬមិនពិតប្រាកដ បើមេកងអនុគ្រោះទៅ មេខ្លះចិត្តល្អគាត់ក៏អនុគ្រោះទៅ មេកងខ្លះ ហៅថា ដេញជើងអញ្ចឹងទៅ ថាយកបាយទៅស្រែ ឲ្យអ្នកជំងឺហ្នឹងតាមទៅហូបនៅ ស្រែភាគច្រើនគឺអញ្ចឹង បាទ!ហើយក្នុងម៉ាវរអីហ្នឹងគឺមានពេទ្យម្នាក់ ពេទ្យហ្នឹងគឺដកពី ពេទ្យកងចល័តនេះយកទៅរៀននៅ៣២បាត់ដំបង ក្នុងរយៈពេលប្រហែលជា៦ខែ ឬមួយឆ្នាំ ពេទ្យហ្នឹងគឺមានតួនាទីចាំព្យាបាលបងមកងចល័តហ្នឹង ប៉ុនពេទ្យហ្នឹងត្រូវមាន

ធុងទឹក អាធុងគុយទាវយើងលក់តាមផ្សារ ធុងនឹងគឺដាំទឹកម៉ង អនាម័យណាស់អត់ឲ្យហូបទឹកឆៅអីទេ អ៊ូ!អារឿងអនាម័យប៉ុនម៉ងពូកែ ។

ដានី : អញ្ចឹងកងចល័តទាំងអស់ហ្នឹងហូបទឹកក្តៅ?

សៅ : ហូបទឹកក្តៅ ពេទ្យដាំទឹកនៅហ្នឹងម៉ង ហើយនរណាមានខ្យល់អីពេទ្យកោសហ្នឹង ។

ដានី : កោសខ្យល់?

សៅ : មិនមានជាថ្នាំអី អត់មានអីទេ ក្រៅពីថ្នាំបុរាណ ខាងពេទ្យហ្នឹងគាត់ច្នៃប្រឌិត ។

ដានី : ចុះព្រះអង្គ កាលហ្នឹងព្រះអង្គមានតួនាទីអីដែរឬអត់ទេ?

សៅ : កាលហ្នឹងអាត្មាក៏មេក្រុមៗ មិនដែលបានអីទេ ។

ដានី : មេក្រុមៗមានគ្នាប៉ុន្មាននាក់?

សៅ : មេក្រុមហ្នឹងពី១០ទៅ១២ ។

ដានី : ពី១០ទៅ១២នាក់?

សៅ : ៣រ ។

ដានី : កាលជំនាន់ហ្នឹងដូចថាមាន ដូចថាយុវជនយុវនារី ត្រូវបានគេចាប់យកទៅធ្វើទារុណកម្មឬក៏សម្លាប់អីទេ?

សៅ : មាន! ណែភាគច្រើនមិនបានមានឃើញនៅទីហ្នឹងទេ ក៏ប៉ុនថាមានការឧទាហរណ៍ថា ហ៊ូ! ថ្ងៃលាចឡើង ឡើងពីពលកម្មដើម្បីទៅកន្លែងមូលដ្ឋានសម្រាក់វិញអីអញ្ចឹង ជួនកាលមេកងឬក៏មេវរៈអីគេថាមិត្តនេះ ត្រូវទៅយកបន្លែ ឬក៏ទៅបើកចប ឬក៏អីយើងមើលទៅឲ្យឃើញតែប្រក្រតី មិនប្រក្រតីហ្នឹងហើយ ទៅហើយគឺមិនដែលឃើញមកវិញទេ តែបើថាឲ្យឃើញធ្វើទារុណកម្មអីនៅទីនោះអត់មានទេ ។

ដានី : អ៊ើ!ដោយសារអ្នកដែលត្រូវគេហៅទៅបើកចប បើកបន្លែហើយ ទៅបាត់ហ្នឹងច្រើនតែសមាសភាពយ៉ាងម៉េច?

សៅ : គឺមែនទែនទៅនិន្នាការនយោបាយ កាលពីឆ្នាំ៧៥មិនសូវជាអីទេ ចូលដល់៧៦គឺអ្នកដែលទៅនឹងភាគច្រើន អ្នកដែលមានអំណាចក្តាប់ត្រឹមមេវរៈឬក៏មេកងធំហ្នឹងដូចថាមិនត្រូវឬកគ្នា និយាយឲ្យសាធូទៅចុះ បុគ្គលនឹងមិនមែនជាទៅបំផុសបំផុលនយោបាយឬក៏សម្តែងនិន្នាការអីទេ ដូចតែគេ ដូចតែញោមអីហ្នឹង អ្នកនៅផ្សាយគរគោកគរដីម៉េច ក៏គេមិនហៅផង ក៏ហៅទៅតែគ្នា មើលទៅមិនមែនជានាយទុន មិនមែនជាអនុធនមិនមែនជាសក្តិភូមិទេ គឺកសិករក កម្មករដែលហ្នឹង ឬក៏មូលធនអី ឪពុកគ្រូអីហ្នឹងឬក៏

ជាកាត់ដេរកាត់អីហ្នឹង គរគោកគរដីហ្នឹង ប៉ុន្តែតាមអាត្មាសង្កេត មិនមែនតែអាត្មាសង្កេតទេ សូម្បីតែខ្លួនឯងហ្នឹងក៏ត្រូវប្រយត្ន័ដែរ ពីព្រោះអំណាចនៅលើបុគ្គល ឧទាហរណ៍ញោមក្តាប់មេកងតូចឬក៏កងធំអញ្ចឹង ដូច្នេះហ្នឹងរាយការណ៍បន្តិចទៅ ព្រោះគោលនយោបាយគឺ ទុកក៏មិនចំណេញ ដកចេញមិនខាតហ្នឹងគឺខ្ទាំង និយាយខ្ទាំងមួយមាត់គឺ ដូច្នេះបើអ្នកមានអំណាចដូចថាមិនពេញចិត្តនឹងញោមអញ្ចឹង!ដូចថាវាទាស់ចរិកគ្នាឬក៏តមាត់តកឬក៏អីនោះ ដូច្នេះអំណាចស្លាប់រស់នៅលើប្រធានវរៈ អានេះក្នុងជួរចល័តនៅលើប្រធានកងធំហ្នឹងហើយ ឬក៏ជួនកាលគេមាន មានដែរៗមានថា ប្រវត្តិរូបពីខាងគល់ហ្នឹងម៉ោ អាហ្នឹងក៏មានដែរ គេស្រាវជ្រាវម៉ោថាមាននិន្នាការអី លន់ ណុល លន់អី ទាហានអី ពីសង្គមចាស់អីអញ្ចឹងទៅណា៎ អាហ្នឹងក៏មានដែរ មិន មែនថាទំនាស់តែតែភាគច្រើនហ្នឹង គឺតែមួយមេហ្នឹងអត់បានម៉ង់ ។

ដានី : ដូចថាគេអត់ចូលចិត្តអីហ្នឹង អាហ្នឹង?

សៅ : ហ្នឹងហើយ!ជួនកាលគាត់ហ្នឹង ហើយដូចគ្នាដែរគឺនៅក្នុងហ្នឹងគឺ ធ្វើការអីជួបជុំជាមួយសហករណ៍អីដែរ ជាមួយសហករណ៍ក៏មិនខុសគ្នាដែរ ប្រធានសហករណ៍ហ្នឹងគាត់មិនពេញចិត្តអកណាហើយហ្នឹងគឺ មានសិទ្ធិ ដូច្នេះអំណាចនៅត្រង់ហ្នឹង អត់មានប្រព័ន្ធតាមដានណាដែងអត់មានទេ ។

ដានី : ព្រះអង្គកាលជំនាន់ហ្នឹងបាត់ខ្លួនច្រើនដែរឬអត់ ក្នុងកងចល័តដែលព្រះអង្គធ្លាប់ធ្វើការជាមួយហ្នឹង?

សៅ : កងចល័តនិយាយសាធូទៅមិនសូវជាច្រើនទេ មិនដល់១០ភាគរយនិយាយសាធូព្រោះកម្លាំងហ្នឹងកម្លាំងផលិតស្រូវសំបើមណាស់ ស្រូវគឺថាចាប់ពីយើងនេះទៅព្រៃណានេះៗ ចបស្មៅណានេះចប ទំនប់ខែនដោនអីហ្នឹងទប់ដោយដៃទាំងអស់ ប្រពន្ធ័ប្រឡាយឈើ ត្រង់ដូច្នេះកម្លាំងនេះកម្លាំងសំខាន់ណាស់ នឹងហើយទាល់តែចបអីមែនទែន ហើយដល់ឆ្នាំ៧៧ហ្នឹងៗដកអស់ច្រើនណាស់ រើសកងទ័ព យកទៅទប់ទល់ព្រំដែនខាងកើត ហ្នឹងគឺម៉ោខាងបាត់ដំបងរទេះភ្លើង អាហ្នឹងដាក់ហ្នឹងហើយរើសគឺប្រកាសទៅទប់ទល់ ហើយក៏ម្នាក់ៗគឺពេលហ្នឹងចង់ឲ្យតែគេហៅទេ ព្រោះកងទ័ពវាឆ្អែត ហើយវាអត់ហត់នឿយអត់ហត់នឿយដូចកងចល័តទេ គឺម៉ោង៨ហ្នឹងដល់ម៉ោង១១បានហូបបាយ សម្រាក១ម៉ោង ម៉ោង១ចុះ យប់ៗចេះពេលសម្រុកកាប់ទាំងយប់ៗម៉ង់មើលទៅខែភ្លឺចបសកាប់ប៊ិតៗអ៊ូស៎ ។

ដានី : ចុះព្រះអង្គកាលហ្នឹងមានបានគេជ្រើសរើសទៅធ្វើកងទ័ពនៅខាងកើតដែរឬអត់?

សៅ : អត់!គេជ្រើសរើសតែធ្វើពេទ្យដែរ តែកាលនោះគ្រូនអត់បានទៅ ។

ដានី : ចុះព្រះអង្គទំនប់ ម៉ក់ ហើន ហ្នឹងមានក្រុមកងចល័តមានទៅលើកដែរឬអត់?

សៅ : សុទ្ធតែចល័តហើយហ្នឹងៗហើយ កងទ័ពតិចតួចណាស់ កងទ័ពម៉ោមើលដូចថាម៉ោចូលរួមផង ម៉ោការពារខ្លាចពួកកងចល័តខ្លាចរត់ខ្លាចអីផងអញ្ចឹងទៅណា៎តាមមើល ។

ដានី : ករុណា!

សៅ : ហ្នឹងហើយតិចណាស់ សុទ្ធតែកងចល័តទាំងអស់ អាម៉ក់ ហើន យើងទៅហ្នឹង ហ្នឹងហើយបាក់ ពេលខែវស្សាញោមវេទនាណាស់ញោម ម៉ោង១០-១១យប់១២យប់ វែកងងឹតណាស់ ទប់ដើម្បីទប់ទំនប់ ម៉ក់ ហើនហ្នឹង ជួនកាលដាក់បង្គីៗហ្នឹងធុងសាំងធុងសាំងយើងកាត់ធ្វើជាបង្គីទំងន់ប៉ុនបង្គីហ្នឹង យ៉ាងតិច១០គីឡូ១គូហ្នឹង ហើយជួនកាលដាក់ដីទៅដាក់ខុសបង្គី ហើយអ្នកវែកក៏ចេះតែវែកទៅ វាហួសកម្លាំងៗឥតឧបមា ។

ដានី : ទំនប់ ម៉ក់ ហើន ពីត្រឹមណាដល់ត្រឹមណាទៅ?

សៅ : ពីត្រង់ហ្នឹងទៅ ទៅទល់យើងគេហៅថា យាងៗហ្នឹង ពីយាងហ្នឹងទៅទល់ភ្នាម៉ក់ ហើនវែងដែរ វែង ។

ដានី : លើកប៉ុន្មានទៅ ពីឆ្នាំណាដល់ឆ្នាំណាបានហើយ?

សៅ : ឆ្នាំដូចលើក៧៦-៧៧ ។

ដានី : ឆ្នាំ៧៧ហើយ?

សៅ : ៧៧ហើយបបូរណ៍ហើយ ។

ដានី : ព្រះអង្គ ដូចថាមានខាងអ្នកដឹកនាំអីដែលគេចុះម៉ោមើល ម៉ោទស្សនៈកិច្ចឬក៏យ៉ាងម៉េចដែរ ដូចថាខាងភូមិភាគឬក៏ខាងពីមជ្ឈិមអីគេមានដែរចុះមោមើលទេ?

សៅ : ដូចជាៗមិនដែល ស្គាល់ត្រឹមតែគេថាកងពលៗដូចជាសមាសភាពត្រឹមយាយ សួហ្នឹងឬក៏ភាពម៉ោពីនិរតីហ្នឹង ហ្នឹងឃើញប៉ុណ្ណឹង ដូចមិនមានឃើញមាន គ្រាន់តែមានតែឡានៗយើង ឡានអាសុិលអាសុីបហ្នឹងឯងម៉ោដឹកស្រូវច្រើន ហើយដល់ពេលច្រូតហ្នឹងបានហូបដែរ គឺគេឡើងឲ្យដល់៣កំប៉ុង រដូវច្រូតកាត់ ។

ដានី : ពេលរដូវច្រូតកាត់ហ្នឹង ប្រមូលផលហ្នឹងយើងបានហូប?

សៅ : បាន៣កំប៉ុង ។

ដានី ៖ ចុះព្រះអង្គកាលជំនាន់ហ្នឹង ព្រះអង្គធ្លាប់បានដូចថាយើងអ៊ើបែកពីឪពុកម្តាយអញ្ចឹងបានទៅលេងជាមួយឪពុកម្តាយដែរឬក៏អត់ទេ?

សៅ ៖ ណេ៎!អត់មានឱកាសទេ កាលដែលអាត្មា ឆ្នាំ១៩៧៦អាត្មាកាលហ្នឹងកើតជំងឺគ្រុន គេដឹកម៉ោមន្ទីរពេទ្យមង្គលបុរីយើង ប៉ុនមន្ទីរហ្នឹងអត់មានអាមន្ទីរពេទ្យដប៉ុនយើងសព្វថ្ងៃ ទេ ផ្សារម៉ង ផ្សារមង្គលបុរីចាស់ហ្នឹងយកដាក់អ្នកជំងឺ ហើយដល់ពេល អាត្មាចាំបានដូចជាខែ១០ ខែ៦ ឆ្នាំ១៩៧៦ហ្នឹងប្រហែលប៉ុន្មានជាខែ១០ធ្លាក់រំហើយហើយហ្នឹងក៏ចេញពីពេទ្យទៅ បានសុំសំបុត្រពេទ្យ ដាក់ថាសុំទៅរកថ្នាំបុរាណនៅភូមិដំបូកក្នុងហ្នឹងមួយអាទិត្យ ហ្នឹងក៏គេដាក់សំបុត្រហ្នឹងទៅ បានយើងធ្វើដំណើរទៅបានមានបាយហូបតាមផ្លូវ បើអត់សំបុត្រហ្នឹងត្រូវមានគេចាប់គេចង ចោទប្រកាន់គ្រប់សព្វប្រការ ហ្នឹងតាំងពីហ្នឹងហើយម៉ោក៏អត់ដែលជួបជុំគ្រួសារទៀតទេ ជំនាន់សម័យហ្នឹង ។

ដានី ៖ ចុះព្រះអង្គដល់ពេលបែកឆ្នាំ៧៩ហើយ ពេលដែលដូចថាយើងជ្រួលច្របល់ពេលហ្នឹងយួនចូលមកដល់ភ្នំពេញ ហើយរត់ម៉ោអញ្ចឹង កាលហ្នឹងម៉េចបានកងចល័តអត់មានបែកខ្ញែកគ្នា អត់រត់ចេញ?

សៅ ៖ ដូចអាត្មាជំរាបអញ្ចឹង ពួកកម្លាំងលែបែកពីទីក្រុងភ្នំពេញហ្នឹង ដោយមានស្នួលមេៗដូចជាលោក សូរ ហុង ដូចជា ពេជ្រ ជឿង លោកអ៊ើ គ្រួសារគាត់ឈ្មោះ មីង សែៗ ហ្នឹង ហើយនឹងលោក នី កនៗ ដែលមេធំៗមានលោកនី កន ហើយនឹងលោក សូ ហុង មានពេជ្រ ជឿង ហ្នឹង ហើយនឹងមានណែ៎ពូ ខុន នេះឈ្មោះអីទេ ហៅលោក ខុនៗ ស្អីមានចាន់ យូរ៉ាន់ អើ!មិនមែនតា ចាន់យូរ៉ាន់ទេ មួយទៀត ដូច្នេះគាត់ ម៉ោៗចងក្រងប្រមូលកម្លាំងចល័តហ្នឹងរត់ រត់បានម៉ាស្រុកខ្លះដែរ ពេលដែលយួន ចូលម៉ោដល់ហ្នឹងអ្នកណាអត់រត់ភាគតិចដែលមិនព្រមមកតាមគេហ្នឹងគឺ រើសបំរាស់រត់ រត់ចូលម៉ោខាងតំបន់ដែលថាមករកស្រុកឪពុកម្តាយវិញនោះណា៎បានតិច ថា១០ ភាគរយចុះប៉ុណ្ណឹងឯងក្រៅពីហ្នឹងគាត់ចងក្រងយកទៅបំពាក់អាវុធហ្នឹង ដូចអាត្មាជំរាប ខាងដើម ។

ដានី ៖ ចុះព្រះអង្គពេលហ្នឹងដូចថាៗ ព្រះអង្គចូលទៅក្នុងកងណាពីដំបូង?

សៅ ៖ ដំបូងគេរៀបជា ក្លាយពីកងចល័តម៉ោគេហៅថាកងឈ្លប ដូច្នេះកម្លាំងហ្នឹងដដែល កម្លាំងក្រុម ពួកចាស់ដដែល គ្រាន់តែថាបន្ថែមថ្នាក់ដឹកនាំម៉ោ ហើយប្រែពីកងហ្នឹងទៅជាកងឈ្លប ដំបូងកែទាំងអស់អត់មានបង់ទេ គ្រាប់ហ្នឹងញុកមួយគ្រាប់ៗ ប្រមូលកម្លាំងអស់ហ្នឹងមកទប់ ម៉ាផ្លូវដល់យើងស៊ីងសំរោង អូរតូច អូរជ្រៅនេះ ។

ដានី :	គេហៅអូរជ្រៅ?

សៅ :	ហ្នឹងហើយ!ទប់ហ្នឹងទប់ដល់ខាងនោះណា៎!យួនអត់ទាន់ឆ្លងទៅបានទេ អត់ទាន់ឆ្លងទៅរាគ្នាទៅរហូត ម៉ក់ ហើន អញ្ចឹងទៅ ដូច្នេះហ្នឹងខាងកម្លាំងខាង គេថាខ្លាំងហ្នឹង នៅតែតាមផ្លូវជាតិលេខ៥ហ្នឹងរហូតទេ ឯទៅសំរោងក៏ទៅអត់បាន ដូច្នេះយកកម្លាំងពួកចល័តហ្នឹងដែលមាំ ហើយនឹងពួកកម្មករៗនៅតាមរោងចក្រភ្នំពេញ ដែលពួកកម្មករហ្នឹងម៉ោម៉ាចំនួនបូកគ្នា បូកគ្នាហ្នឹងកម្លាំងតាំងពីហ្នឹងពង្រាយទៅដល់ប៉ៃលិននោះ ។

ដានី :	រាយយើងរាយជាខ្សែ?

សៅ :	ពរ!រាយដល់ស្រែអន្ទាក់ ដល់ប៉ៃលិនអញ្ចឹងទៅ ហើយកម្លាំងសេសសល់ប៉ុន្មានហ្នឹងក៏ប្រមូល ដូចថាអ្នកណារត់ៗចេញពីខ្មែរក្រហម រត់ម៉ោហ្នឹង អ្នកណាដែលទៅខាងនោះគឺរៀបកម្លាំងហ្នឹងទប់ស្កាត់ ដល់តែខែប៉ុន្មានទេ អាគ្នាចាំអត់បាន ដូចជាខែ៦ខែ៧ហើយបានកម្លាំងខាងយួនហើយ ប្មុកម្លាំងខត្តរុញៗដល់ព្រំដែន ។

ដានី :	ខែ៦ ខែ៧ ឆ្នាំ៧៩ដដែល?

សៅ :	៧៩ដដែល រុញៗដល់ ដូច្នេះតាំងពីខែ១ទៅ អត់ទាន់ធ្វើអីកើតទេ នៅយើងម៉ាជួរយើងដងស៊ីងសំរោង គុកតូចគុកធំអីហ្នឹង ម្នាងស៊ីងម្នាក់ហ្នឹង ពួកហ្នឹងនៅខាងនោះ ពួកនេះនៅខាងនេះទៅ ឃើញគ្នាបាញ់ស៊ីគ្នារាល់ថ្ងៃអញ្ចឹងទៅ ហើយក៏ឯងនារីៗកម្មករអីហ្នឹងក៏គាត់ដាក់ស្នាក់ការកម្លាំងដឹកជញ្ជូន កងស្អែងគេហៅថាកងស្អែងនោះ អ្នកណារបួសអីគេសែង ឧទាហរណ៍ថាពាគីឡូដល់ស្នាក់ការមួយទៅ សែងបន្តទៀតទៅ មិនស្រួលៗទៅដាក់នៅមូលដ្ឋានខាងក្រោយម្តុំយើងអូរស្រឡៅអីនោះមន្ទីរពេទ្យបង្អែក ។

ដានី :	នៅណា?

សៅ :	នៅអូរស្រឡៅយើងផ្លូវទៅម៉ាឡៃហ្នឹង គេហៅថាភូមិអូរស្រឡៅ ដំបូកវិលអីហ្នឹង អូរស្ព័រអីហ្នឹង ។

ដានី :	អ្ហ៎!ស្គាល់ហើយ ។

សៅ :	ហ្នឹងកម្លាំងយើងវ៉ៃនៅជួរមុខ ប៉ុន្តែស្នាក់ការពេទ្យនៅនោះ ហើយដូច្នេះដឹកជញ្ជូនអ្នករបួសហ្នឹងគឺដោយកងស្អែងសុទ្ធសាធតែតំណាង ញោមនេះទៅផ្តាំទៅ អ្នកផ្តាំហ្នឹងបន្តទៅថ្មពួកទៀតទៅ ហ្នឹងហើយមិនថាយប់មិនថាថ្ងៃ ដូច្នេះចាំទទួលពីនេះទៅ អត់មាននេះទេ ។

ដានី :	កាលហ្នឹងយើងបែងចែកជាកងពលជាអីប៉ុនៅ?

សៅ ៖ កាលហ្នឹងអត់ទាន់ទេ ដល់ទៅរៀបៗព្រំដែន ។

ដានី ៖ ករុណា!

សៅ ៖ ពរ!រៀបៗដែលធ្លាប់បែកបាក់ហើយ រៀបឯព្រំដែន ជួរម៉ាឡៃ ភ្នំបឹងប៉េង ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយទៅរៀបហ្នឹង ហ្នឹងរៀបខាងតូ កន ហ្នឹងក៏រៀបខាងហ្នឹងទៅ ហើយខាងនេះក៏មានឯកឧត្ដម សុខ ភាព នេះគាត់រៀបខាងនេះម៉ោ ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ ក្នុងហ្នឹងក៏មានតូ កន ហើយមានរង់ៗកងដូចជាតាពុធ តាអីហ្នឹងទៅទៀត ទៅហើយខាងនេះក៏រៀបបានកម្លាំងហ្នឹងហើយរៀបកម្លាំងពិសេសខ្លួនអាត្មាផ្ទាល់ហ្នឹងទៅដកដូចជាពាវរៈ ។

ដានី ៖ ពាវរៈ?

សៅ ៖ ពរ!ពាវរៈៗហ្នឹងពីម៉ាឡៃៗហ្នឹងដល់វរៈដែលដល់ព្រំដែនហ្នឹង១៩០០ខែ ប៉ុន្មានទេចាំមើលខែ៧៥ហើយ ចូល៧៦ហើយ ប្រហែលខែ១២ទៅ១ ៧៥ហ្នឹង ដូច្នេះខាងអាត្មាហ្នឹងប្រហែលជាពាវរៈដក ដឹកយកទៅចុះអូរអង្ក្រែរៗដែលខាងលិចអន្លង់វែង បន្តិច ។

ដានី ៖ ករុណា!ស្គាល់ៗ ។

សៅ ៖ ហ្នឹង!ព្រោះកាលហ្នឹងខាងកម្លាំងអាត្មាហ្នឹងគេដកទៅហ្នឹងគឺ ដោយខាងលោកនួន ជាគាត់បើកប្រកខាងនោះមួយ លោក អៀង សារី ឯកឧត្ដម អៀង សារី ហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ គាត់បើកប្រកមួយខាងនោះ ថ្នាក់ដឹកនាំ បើកប្រកចេញពីភូមិប្រាច់ ពីថៃទៅ នៅស្រុកនៅខេត្តសូរិន ប៉ុនចុះតាមសុខៈ ទៅខាងភូមិប្រាច់ ភូមិតាវែងហ្នឹង ភូមិដែលគេបោះបង់ចោលនៅថៃហ្នឹង តែយើងនៅទឹកដីខ្មែរទេ តែព្រំប្រទល់ត្រង់ហ្នឹង ដូច្នេះគាត់ទៅបើកមន្ទីរប្រកមួយត្រង់ហ្នឹង របស់លោក អៀង សារី ។

ដានី ៖ គេហៅមន្ទីរអីគេត្រង់ហ្នឹង?

សៅ ៖ អុឺ!ហ្នឹងគេហៅថាមន្ទីរទឹកធ្លាក់អត់មានលេខទេ ។

ដានី ៖ ហៅមន្ទីរទឹកធ្លាក់?

សៅ ៖ ហ្នឹងហើយ មន្ទីរទឹកធ្លាក់ហ្នឹងគឺវាមានអាគន្លែងចន្លោះភ្នំហ្នឹង មានទឹកធ្លាក់ អូរអង្រែរ នៅអាកន្លែងទឹកធ្លាក់ហ្នឹង ហើយលោក អៀង សារី គាត់បើក ដោយបើកផ្សាភ្ជាប់ពីខាងតាម៉ុកម៉ោដងៗ សហការណ៍ជាមួយតាម៉ុក ។

ដានី ៖ ករុណា!

សៅ ៖ ហើយកម្លាំងខាងលោក អៀង សារី ដល់មែនទែនទៅត្រង់ហ្នឹងផង គាត់ ដូចជាកន្លែងហ្នឹងដូចជាមន្ទីរទេ ប៉ុន្តែគាត់គ្រប់គ្រង់ដូចជា អប់រំនយោបាយពួកកងទ័ព របស់តាម៉ុកដែលជាមូលដ្ឋានចាស់ហ្នឹងផង ហ្នឹងហើយគាត់ប្រមូលទៅហ្នឹង ហើយឆ្នាំ៧៦-៨០-៨១អីហ្នឹងលោក នួន ជា ទៅបើកសាលានយោបាយនៅទីនោះ ហ្នឹងហើយ ម៉ែក៏គាត់បានចូលរួមដែរ នួន ជា អប់រំថ្នាក់កម្មាភិបាលៗហ្នឹង អប់រំមានមន្ទីរមួយអប់រំប្រកស្លឹកចាកហ្នឹង គាត់ទៅអប់រំប្រហែលជា៣ខែ ហើយត្រង់ហ្នឹងកាលលោក អៀង សារី បើកហ្នឹងគឺ កន្លែងទទួលភ្ញៀវបរទេសផង គឺពួកមានអាឡឺម៉ង់ មែនទែនឲ្យតែភ្ញៀវពួកបរទេស មិនមែនជាតែចិនទេណា៎ គឺជប៉ុនក៏មានទៅដែរ ជាគណៈៗកន្លែងហ្នឹងគឺពួកអាត្មាទៅហ្នឹងគឺការពារ ម៉ាវរៈជាងពីរវរៈហ្នឹងគឺការពារនៅគឺជាផ្ទះលេខបូកហ្នឹង នៅមន្ទីរទឹកធ្លាក់ហ្នឹង ហើយភ្ញៀវទៅអី ពួកអាត្មាហ្នឹងក៏គេកាត់ពីទ័ពហ្នឹងចូលមន្ទីរលោក អៀង សារី តាំងពីពេលនោះម៉ោ ហ្នឹងហើយ ។

ដានី ៖ ហ្នឹងគេហៅ ផ្ទះលេខបូក?

សៅ ៖ ផ្ទះលេខបូក ហ្នឹងកន្លែងអាត្មានៅហើយ ហ្នឹងមានលោក សូរ ហុង គាត់នៅហ្នឹង ប៉ុន្តែជាចូលទៅជ្រោកន្លែងទឹកធ្លាក់នឹង ដូចជាអៀង សារី ខៀវ សំផន គ្រួសារលោក ខៀវ សំផន ឈ្មោះអី មីង រិន ហ្នឹង គាត់ទឹមរើកន្លែងដែរ នៅដល់៨២ ខែ៦ បានរើប្រគល់ទឹកដីហ្នឹងឲ្យតាម៉ុកវិញ ។

ដានី ៖ ករុណា!

សៅ ៖ ហើយបានពួកអាត្មាអីនេះ ពួកកម្លាំងមន្ទីរទាំងអស់នេះម៉ោម៉ាឡៃវិញ ខែ៦ ១៩៨២ ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ ។

ដានី ៖ ហើយម៉េចទៀតទៅព្រះអង្គ?

សៅ ៖ ហ្នឹងហើយ អាត្មាដល់ពេលម៉ោៗដល់ម៉ាឡៃនេះ សម្រាប់ផ្ទាល់ខ្លួនអាត្មាក៏អៀង សារី នេះចាប់មួយក្រុម ១៩៨៣ ខែ៤ កាលនោះខ្ញាំងវៀតណាមយកច្រកចំការគរភ្នំឆត្រ

នេះអស់ហើយ ត្រូវដាច់ៗប្រពន្ធ័ដឹកជញ្ជូនពីខាងប្រទេសថៃម៉ោ ដាច់អស់កម្លាំងកងពល៥១៩នេះ មួយកងពលនេះៗប្រចាំមុខសញ្ញាទាំងអស់ហ្នឹង ទាំងអស់ៗទល់គ្នាទាំងអស់នេះគឺកងពល៥១៩ហ្នឹង ដែលមានលោក យន ជាប្រធានកងពល លោក ឌុល សារឿន ដែលនៅសព្វថ្ងៃនេះ នៅស្វាយនេះជាអនុ ។

ដានី : ករុណា!

សៅ : ហ្នឹង!ហើយដល់ពេលដាច់នេះ លោក អៀង សារី គាត់ បានឲ្យមិត្តថែម នោះគាត់ស្លាប់ហើយ ឡុង ថែម ។

ដានី : ឡុង ថែម?

សៅ : ហ្នឹងហើយ ស្គាល់ ឡុង ថែមដែរ?

ដានី : ករុណា!

សៅ : ហ្នឹងហើយ គឺគាត់នោះប្រធានហើយ អាត្មាហ្នឹងក៏ជាបន្ទាប់គាត់ដែរ អៀង សារី ចាប់ម៉ោឲ្យទូរលេខសម្រាប់ទាក់ទងណា៎ អាវិរៃ វិទ្យុនីបហ្នឹងណា៎ ម៉ោចុះជួយសម្រួលច្រកខាងព្រំដែនថៃ ផ្សារភ្ជាប់ពីកម្លាំងហ្នឹងទៅលោកតា អៀង សារី ។

ដានី : ករុណា!

សៅ : ហ្នឹងហើយ ដូច្នេះពួកអាត្មានេះមួយក្រុម ម៉ោប្រហែលជា១០នាក់ មានក្រុមទូរលេខនេះហើយ លោកថែមនេះគាត់ជាមេដឹកនាំមកផ្សារភ្ជាប់ៗគឺសំខាន់ហ្នឹងគឺ វិបែកបាក់អស់ហើយ គឺកម្លាំងហ្នឹងគឺមិនដឹងត្រង់ណាទេ ហើយម្យ៉ាងទៀតហ្នឹងខ្វាចចូលនឹងខាងភាគី TP ផង ខ្វាចចូលទៅប៉ារ៉ាដងណា៎ ដូច្នេះវាដាច់រយៈហើយ ព្រោះបែកគាំងពីចំការគរនេះទៅទល់គ្នាយើងឡាក់៣២ ខាងជើងបឹងត្រកួននេះណា៎ ហ្នឹងគឺ៥១៩គាត់អ្នកកាន់កាប់ ដូច្នេះអាត្មាម៉ោហ្នឹង ម៉ោចុះត្រឹមបឹងត្រកួននេះ ឡាក់៣៣-៣៤ហ្នឹងម៉ោហ្នឹងក៏សម្រួលៗបាន បើកច្រកថៃ បាន ហ្នឹងហើយដឹកជញ្ជូនស្បៀងអាហារគ្រាប់រំសេវអីចុះតាមហ្នឹង ។

ដានី : ករុណា!

សៅ : ហ្នឹងហើយ ឯគ្រួសារយុទ្ធជនក្នុងកងពល៥១៩ហ្នឹងខ្វះក៏ទៅជំរុំ ។

ដានី : ករុណា!ទៅជំរុំណាទៅ?

សៅ : កាលហ្នឹង ខ្វះក៏ទៅជំរុំថ្មី ជំរុំកាកបាទក្រហមហ្នឹង ។

ដានី : ករុណាៗ!

សៅ ៖ ហ្នឹងហើយ កាកបាទខ្លះទៀតក៏មានកាន់ខាងលោក អៀង សារី ដែលណាំ ចាប់ឲ្យដឹកយកទៅដាក់នៅម៉ាឡៃ ម៉ាចំនួន ហើយក្រោយបានប្រមូលគ្នាបណើរៗ បានបំបែកទៅប្រមូលគ្នានៅអូរស្រឡៅយើងហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ នឹងខាងកម្លាំង៥១៩ ហើយអាត្មាក៏មានភារកិច្ចអ្នកទំនាក់ទំនង ។

ដានី ៖ ទំនាក់ទំនងយ៉ាងម៉េចព្រះអង្គ?

សៅ ៖ ទំនាក់ទំនងរវាងថៃនឹងគឺថាបើមែនទែនទៅបើយើងហៅភាសាសាមញ្ញគឺថាម្ចាស់ច្រក គឺអ្នកទំនាក់ទំនងហ្នឹងគឺសម្រួលការទាំងអស់ក្នុងរវាងគ្រួសារអីនៅឯម៉ាឡៃនោះ ត្រូវការឡើងម៉ោហើយប៉ុន្មានខែអីមានការឡើងអីទៅលេងគ្រួសារអី គឺអាត្មាហ្នឹងអ្នកទំនាក់ទំនងឡាន រត់តាមដីថៃហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ រត់ទៅឬក៏អ្នករបួស ។

ដានី ៖ ករុណា!

សៅ ៖ របួសណាថ្នាក់កម្មាភិបាលទៅ ថ្នាក់មេបន្តិចទៅក៏យើងហៅឡានពេទ្យយើង តែបើយុទ្ធជនអីធម្មតាបន្ទាន់ៗហៅកាកបាទក្រហម ដេកក្រោយដារហ្នឹង នឹងទំនាក់ទំនងខាងហ្នឹង ហើយដល់ពេលអាត្មាចល័តដែរ ជួនកាលទៅក៏ម៉ោប្រចាំការម៉ាឡៃ ជួនកាលដកពីម៉ាឡៃទៅអាងក្បាលឡាវយើងនេះ ហៅថាច្រកគប់គីរណាំ!

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ!មែនទែនទៅ អាត្មាតាមសភាពការណ៍អាត្មាតឹង លោក អៀង សារី អៀង វុធ ។

ដានី ៖ ករុណា!

សៅ ៖ អៀង វុធ កូនគាត់ បងវុធហ្នឹងហើយគឺអាត្មាជាប់ជាមួយគាត់ហ្នឹង ហើយដល់អាត្មាតឹងគាត់រុញអាត្មាដាក់ទៅហ្នឹងហើយ ចង់និយាយថាតឹងហ្នឹងទំនាក់ទំនងច្រកថៃនឹងខ្មែរ អាកម្លាំងយើងចេញចូលវាលំបាក ឬក៏សភាពការណ៍ព្រំដែន ខ្មែរយើងមានទៅលួចទៅប្លន់ ឬក៏គេចោទប្រកាន់អីអញ្ចឹងទៅ ឬក៏ចូលដីគេដីអី ទៅទាំងឯកសណ្ឋានទៅអាជ្ញាធរថៃគេចាប់អីទៅមានអាត្មាហើយ គេអ្នកទំនាក់ទំនងហៅថាគណៈទាក់ទង ហ្នឹងគឺ

អញ្ចឹងអាត្មាហ្នឹង បន្រ្ទមតិចចុះ ហើយដល់ពេលអើផ្ដាច់ខ្លួនយើង អាត្មានៅម៉ាឡៃ ហើយនៅម៉ាឡៃហ្នឹងក៏មិនបានចូលបំរើអី ចូលសមាហរណកម្មអីទេ គឺថាផ្ដាច់ខ្លួនឯង ។

ដានី : ករុណា!

សៅ : ហ្នឹងហើយ អត់ទៅបំរើ ឈប់ទៅបំរើនិន្នាការនយោបាយខាងនយោបាយ គណៈបក្ស ណា ឬក៏ទៅបំរើយោធាអី នៅក្នុងក្របខ័ណ្ឌយើងទាហានបន្រ្ទបបន្រ្ទមគ្នាហើយហ្នឹង អត់ទេ លះបង់ទាំងអស់ អត់ ម៉ោផ្ទះអាត្មានៅខាងកើតនេះ អាត្មាបានញោម ផ្ទះខាង លិចនេះ កាលហ្នឹងញោមនាំម៉ោស្រុកកំណើតគាត់ហ្នឹង ផ្ទះនេះញោមនៅខាងកើតនោះ ខាងកើតហ្នឹងខាងកើតសាលារៀននេះ ។

ដានី : អ៊ូ!

សៅ : ហ្នឹង ហើយកាលញោមហ្នឹងទៅ ហើយដោយឡែកដែលបួសនេះគឺមានឧបនិស្ស័យព្រះ ពុទ្ធសាសនាហើយតាមដែលអាត្មា មើលណា៎គឺមិនបានហៅថាមានបំណុលអ្នកណា ឬក៏ ខ្វះសមត្ថភាព ដឹកស៊ីចិញ្ចឹមកូចៅរូបខ្លួនឯងទេ ។

ដានី : ករុណា!

សៅ : ឬក៏អត់មានកើតរោគសេដាអីទេ ឬក៏មានទោសខាងរាជការអីអត់ទេ ។

ដានី : ករុណា ៗ!

សៅ : នឹក ៗ នឹងក៏បើយើងនិយាយភាសាធម៌ហៅថា ឧបនិស្ស័យនឹងស្បង់ជ័យវិរហើយ ណាស់ ។

ដានី : ករុណា!

សៅ : ដល់ពេលហ្នឹងឯងក៏ប្រាប់ញោមហ្នឹង អតីតគ្រួសារហ្នឹង ប្រាប់ថាខ្ញុំបំបួសហើយ ហើយ គាត់ថាអើបើបានបួសគាត់អរហើយ គាត់ដើរមករកវត្តហ្នឹង មករកលោក ស្នាល ហ្នឹង ៗ ។

ដានី : ករុណា!

សៅ : ហើយក៏គាត់ហ្នឹងនាំ ញោមក្មេកម្ដាយហ្នឹងហើយគាត់ក៏អីហ្នឹង កូនចៅបងប្អូនអាត្មាម៉ោ ក៏ទៅបួសវត្តស្វាយចេក បួសហ្នឹងគឺដោយតាំងចិត្តថាបួសគឺដោយសារតែ៣ខែទេ យើងចាំម៉ា ត្រីមាសហ្នឹង ។

ដានី : ករុណា!

សៅ : ចាំវស្សាម៉ាវស្សា បាន៣ខែទេ ដើម្បីទូន្មានអារម្មណ៍ហ្នឹងណា៎ ឲ្យវានឹងនរវាមានការ ហៅវាងងឹតងងុលមិនបានពិចារណាផ្លូវធម៌ហ្នឹង ដល់បួសទៅហើយហ្នឹងក៏ចេះតែនៅទៅ

ហើយបានប៉ុន្មានខែហ្នឹងក៏ញាតិ ញោម ហើយនឹងគណៈសង្ឃអីហ្នឹងក៏និមន្តឲ្យធ្វើពិចារការតាំងពីមិនទាន់បាន១២ខែនោះ ការពិតទៅយើងនៅក្នុងព្រះពិន័យហ្នឹង៥វស្សា ៥វស្សាហ្នឹងទាល់តែឆ្លាតឆ្លៀស នឹងហើយប៉ុនដោយខ្សែកអត់មាន ដើរទៅរក អាត្មាជាលោកហើយហ្នឹង ដើរទៅរកនិមន្តវត្តនេះវត្តនោះដែរ ដើម្បីឲ្យលោកម៉ោទទួល ហ្នឹងក៏មិនមាន ដូច្នេះបើវត្តយើងអត់ព្រះចៅអធិការវាមិនកើត ដូច្នេះតាំងពីហ្នឹងម៉ោក៏វាចេះជាប់ភារៈ កាលថា៣ខែហ្នឹង លាបំណន់វាទៅជាភ្លេចអស់ទៅ ដល់តែមានភារៈហ្នឹងម៉ោណាស់!

ដានី : ករុណា!

សៅ : ចេះតែជ្រះថ្លាទៅ ចេះតែជាប់ទៅ ។

ដានី : ករុណាសូមសួរបកទៅតិច អើព្រះអង្គពេលដែលដូចថាកាលហ្នឹង ពេលដែលបែកបាក់ហើយ ដល់ពេលព្រះអង្គទទួលខាងច្រកព្រំដែន ខាងទំនាក់ទំនងខាងថៃហ្នឹង កាលហ្នឹងកងពល៥១៩យើងរៀបចំឡើងវិញយ៉ាងម៉េចដែរ?

សៅ : ណ៎!ការពិតបែកតែទីតាំងទេ តែកងពលអត់រលាយទេ ។

ដានី : ករុណា!

សៅ : ហ្នឹងហើយ បែកតែទីតាំងហើយ កម្លាំងខ្ចាតខ្ចាយហើយ ។

ដានី : ករុណា!

សៅ : ដល់តែពេលពីបហ្នឹង កម្លាំងលោក អៀង សារី បញ្ជូនម៉ោហ្នឹងពីបហ្នឹង ម៉ោសហការជាមួយមេកងពលគឺលោកយនហ្នឹង ហ្នឹងហើយសហការមកបំបែកម៉ាវរៈសេនាធំ គឺ៤០៨ របស់ សេរី សុបិន្ត គឺអភិបាលវង ។

ដានី : ករុណា!

សៅ : ដែលគាត់ស្លាប់ហើយ! ។

ដានី : ករុណា!

សៅ : នេះរូបថតគាត់នៅនេះមានដែរ ហ្នឹងដល់ឥឡូវបំបែកឲ្យយើងទៅចាំនៅជើងភ្នំនោះបានមានកម្លាំងទន្ទេសាបហ្នឹងតាំងពីហ្នឹងម៉ោៗ គាត់ម៉ាវរៈសេនាធំគឺ៤០៨ហ្នឹងគឺដាច់បាត់ ។

ដានី : ៤០៨កាលហ្នឹង?

សៅ : ៤០៨ ហ្នឹងហើយ មាន៤០៥ ,៤០៣ ,៤០១ វរៈសេនាធំ ៤វរៈសេនាធំ ។

ដានី ៖ 	 ករុណា!ដល់ពេលអញ្ចឹងមានបានបំបែកជាកងពល ៥១៨អីទៀតប្អូអត់?

សោ ៖ 	 ណែ!អាហ្នឹងក្រោយទេ ក្រោយទៀត អាហ្នឹង៥១៨ហ្នឹង គឺកម្លាំងឈ្លបៗ ចេះតែបង្កើតទៅ ហ្នឹងហើយ ប៉ុនឯងនេះ៥១៩ហ្នឹង ហើយដល់របស់ សេរី សុបិន្ត ហ្នឹង គាត់ទៅហ្នឹងគាត់ឡើងស្វយ័ត បានន័យថាគាត់ទទួលពីអគ្គបញ្ជាការគឺ ប៉ុល ពត ឬក៏ សុន សេន ផ្ទាល់ គាត់អត់មានម៉ោចំណុះខាង សុខ ភាព សូរ ហុង ព្រោះ សូរ ហុង គាត់គណៈប្រតិភូដែរ ។

ដានី ៖ 	 ករុណា!

សោ ៖ 	 គាត់បានន័យថាក្តាប់៤៥០នេះផង ក្តាប់៤១៩ផង ។

ដានី ៖ 	 ករុណា!

សោ ៖ 	 អាហ្នឹងគេក្តាប់តែ២កងពលទេ ព្រោះកងពលហ្នឹងកងពលធំ ។

ដានី ៖ 	 ករុណា!

សោ ៖ 	 ដូច្នេះរបស់សេរី សុបិន្តដល់ពេលគាត់នេះទៅ គាត់ផ្តាច់ហើយ ដាច់ពី៣២ ដាច់របស់នាយ កន ហើយ ហ្នឹងក៏ឡើងពី សុន សេន ឬក៏បញ្ជាពី ប៉ុល ពត ម៉ោ របស់កម្លាំង៤០៨ហ្នឹង វរៈសេនាធំពិសេស ។

ដានី ៖ 	 ចុះដល់ពេលហ្នឹងគណៈកងពល៥១៩ មានការផ្លាស់ប្តូរម៉េចទៀតទៅ ដូចថា តាយន គាត់?

សោ ៖ 	 ក្រោយម៉ោ តាយន គាត់ត្រូវឪពុកគាត់នៅម៉ាឃីមនោះនៅខាងកោះកុងនោះណា! ។

ដានី ៖ 	 ករុណា!

សោ ៖ 	 ហ្នឹងហើយ គាត់មាន ហើយដោយឡែករបៀបអានេះ អាត្មាស្មានទេណា ដែលត្រូវដកគាត់ទៅហ្នឹងគឺ ដោយសារថាបើយើងនិយាយថាបដិបត្តិវាមិនសូវបាន ប្រតិបត្តិវាមិនសូវបានហ្នឹងហើយ និយាយឲ្យខ្លីទៅ ។

ដានី ៖ 	 តាយន ហ្នឹង ០៦ហ្នឹងមែនទេ?

សោ ៖ 	 តាយន អារឿងលេខគាត់ហ្នឹងលេខ ០៦ដឹង ។

ដានី ៖ 	 គាត់អតីតភាពរបស់គាត់កាលពីជំនាន់៣ឆ្នាំ គាត់នៅខាងមណ្ឌលគិរីមែនទេ អូស៎! កងពល៩២០នៅមណ្ឌលគិរី?

សោ ៖ 	 អេស៎!តាយនដូចអត់ដែលទៅដល់មណ្ឌលគិរីទេ ប៉ុនអាត្មាអត់បាន និយាយសាធូទៅ នៅសម្រាក់ជាមួយគាត់ធម្មតា ប៉ុនថាអត់ដឹងអីទេ ។

ដានី ៖ គាត់មួយទៀត ធ្លាប់អាន ធ្លាប់សម្ភាសន៍អតីតកម្មាភិបាល ដូចថាគាត់ដៃគូរជាមួយតាសាវឿន ០៥របស់?

សៅ ៖ តាសាវឿន ០៥របស់តា ម៉ុក ។

ដានី ៖ របស់តាម៉ុក ។

សៅ ៖ បើតាសាវឿន ០៥ស្គាល់ តាសែន តាសានអីហ្នឹង ។

ដានី ៖ តាសាន?

សៅ ៖ តាសាន គាត់ជាអ្នកទាន់សម័យណាស់ ។

ដានី ៖ តាសាន ០៦?

សៅ ៖ តា វឿន ០៥ តាសានហ្នឹង០៦ តាសែន មួយដែលតាម៉ុក ចាប់ដាក់ទ្រុងដែកនៅអន្លង់វែងនោះណា ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយដែលហៅថាទ្រុងដែកនោះណា តាសាន អាសាវឿនហ្នឹងៗស្គាល់ ធ្លាប់ស្គាល់គ្នាព្រោះ១៩៩៨ អាគ្នាមិនដែលចុះសមរភូមិអីទេ កាលហ្នឹង ឆ្នាំហ្នឹងជាមួយសូរ ហុងទាំងអីជាមួយអាគ្នាហ្នឹងបូកជាមួយសេរី សុបិន្ត បូកជាមួយគ្នាហ្នឹងអ៊ីតា សាន តាសែននឹងតាសាវឿន ០៥ហ្នឹង បូកគ្នាហ្នឹង ខាងតាម៉ុកម៉ោហ្នឹង ហើយខាងមាឡៃ នេះ សូរហុងដឹកនាំផ្ទាល់ហ្នឹង ចុះទៅនៅយើងម្តុំកាន្ទាប់ ចាប់ពីបរមីម៉ោនេះ ចាប់ពីកាន្ទាប់ចុះមកក្រោម ហ្នឹង៩៩៨ ។

ដានី ៖ ហ្នឹងនៅក្នុងខេត្តណាហ្នឹង?

សៅ ៖ នេះនៅមង្គលបូរី ស្រុកមង្គលបូរី ព្រំប្រទល់យើងជាប់ឯកភ្នំ ថ្មគោលខាងនោះ ពរ! ហ្នឹងហើយ ហ្នឹងបូកគ្នាបាន១១ខែដែរ ។

ដានី ៖ ចុះដល់ពេល តាយន គាត់ទៅខាងកោះកុងទៅ គណៈកងពល៥១៩?

សៅ ៖ គណៈកងពល៥១៩ហ្នឹងបែកពី សុបិន្តទៅមាន ឌុល សាវឿននេះឯង ឌុល សាវឿនហ្នឹងមានចៅសុខៗនៅខាង៨២យើងសព្វថ្ងៃនេះ ។

ដានី ៖ ករុណាៗ!

សៅ ៖ ហ្នឹងចៅសុខហ្នឹង ហើយ ឡុង ថៃមហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយអ៊ឺ ព្រំ សូរ ។

ដានី ៖ ករុណា!

សៅ ៖ ព្រាំ សូរ កាលហ្នឹងមិនទាន់ចូលទេ មិនទាន់ពេញសិទ្ធិជាគណៈកងពលទេណាស់ គាត់ឡើងក្រោយទេ ព្រាំ សូរ យើងនេះ ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ ប៉ែន វ៉ូវ ប៉ុនថាហ្នឹងចូលគណៈហើយណា ចូលគណៈកងពលហើយ ប៉ែន វ៉ូវនេះ ។

ដានី ៖ ករុណា!

សៅ ៖ ចូលគណៈហ្នឹងមានលោក ឌុល សារឿននេះជាប្រធានកងពល ។

ដានី ៖ កាលនោះព្រះអង្គមានតួនាទីអីដែរ?

សៅ ៖ ហ្នឹងគណៈទាក់ទងហ្នឹង ។

ដានី ៖ គណៈទាក់ទងរបស់កងពល?

សៅ ៖ របស់កងពល ប៉ុនអាត្មាមិនមែនតែចំពោះកងពលហ្នឹងទេ ៤៥០នេះក៏ម៉ោបាន គឺស្រាប់តែ អៀង វុធ លោកចាត់ចែង ឬក៏សូរ ហុង អានេះគេថាទទួលផ្ទាល់ឬក៏ទទួលភារៈកិច្ចហ្នឹងម៉ោពីសូរ ហុង ឬក៏ អៀង វុធ ។

ដានី ៖ ចុះអ៊ី!ករុណាឆ្លល់បន្តិចម៉េចបាន អៀង វុធ ហើយ សូរ ហុង ទុកចិត្តព្រះអង្គឲ្យព្រះអង្គទទួលខាងហ្នឹង?

សៅ ៖ កាលស្គាល់ សូរ ហុង តាំងពីអាត្មាទៅធ្វើកងឈ្លបបំបែកទៅ សូរ ហុង ហ្នឹងគឺនៅសំរោងយើង ភូមិសំរោង គាត់នៅខាងនោះ ស៊ីងខាងនេះ ព្រោះខាងនេះអាតំបន់ភូមិហ្នឹងវាអត់ប្រទង់ប្រទាញ ។

ដានី ៖ ករុណា!

សៅ ៖ អាខាងនេះនៅខាងផ្ទល់ជាតិ អាខាងនោះអូរ វែអ្នកណាទៅគឺបាញ់គ្នាអញ្ចឹងឯង ហើយស្គាល់គ្នាអញ្ចឹងឯង ហើយដល់តែស្គាល់ដូចជាស្គាល់ជាធម្មតា ។

ដានី ៖ ករុណា!

សៅ ៖ ហើយដល់ពេលទៅដល់៨០៨ ដែលគាត់យកមកនៅជាមួយគាត់ហ្នឹង ដកពីកម្លាំងការពារមកវិញហ្នឹង ម៉ោៗជាកម្លាំងមន្ទីរហ្នឹង អាត្មាចេះភាសាថៃ គេឲ្យអាត្មា ពី៧២ម៉ោ ៧៥ហ្នឹងនៅយើងចៅ្ហយ ប៉ែត ហ្នឹង កាលហ្នឹងថៃចេញចូលទៅអារញ្ញទៅអីហ្នឹងគឺអត់មានយើងលិខិតឆ្លងដែនដូចសព្វថ្ងៃទេ ។

ដានី ៖ ករុណា!

សៅ ៖ របបហ្នឹង ថៃក៏ម៉ោទៅ យើងក៏ទៅៗ ទៅមើលកុនមើលល្ខោនអីនៅផ្សារអារញ្ញហ្នឹង ទៅហើយញោមអាត្មាហ្នឹង ញោមប្រុសគាត់ចាំតវ៉ាន់ទទួលស្ករសឲ្យថៅកែហ្នឹងពីខាងថៃ ហ្នឹងគេដឹកម៉ោ ស្តុកនៅមាត់អូរហ្នឹង ហើយអាត្មាក៏ចេះៗគឺថាចេះភាសាដោយនោះ ហើយដល់តែឃើញត្រង់ហ្នឹង សូរ ហុងគាត់ឃើញអញ្ចឹង គាត់យកមុនដំបូងម៉ោឲ្យគ្រាន់តែបកប្រែទេ ។

ដានី ៖ ករុណា!

សៅ ៖ ដល់បកប្រែទៅ ហៅថាការទទួលហៅការអប់រំរឿយៗទៅ បានឡើងនាទីឡើងឋានៈរឿយៗម៉ោ ។

ដានី ៖ ករុណា!

សៅ ៖ ពរ!

ដានី ៖ ចុះខាង អៀង សារី ដូចថាខាងអៀង សារី ខាងនួន ជា ខៀវ សំផន គាត់នៅណាទៅពេលហ្នឹង?

សៅ ៖ ពេលហ្នឹងគាត់នៅអូរទា នៅកោះកុងជាមួយ ប៉ុល ពត ។

ដានី ៖ នៅខាងអូរទា នៅខាងកោះកុង?

សៅ ៖ ពរ!ហើយប៉ុល ពត ម៉ោនៅភ្នំប្រាក់នេះ ចំមុនសញ្ញាអាត្មានេះ អាហ្នឹងគឺ៨៨ ។

ដានី ៖ ឆ្នាំ៨៨?

សៅ ៖ ហ្នឹងហើយ បានម៉ោនៅនេះនៅក្រោយភ្នំឆត្រហ្នឹង ហ្នឹង សូរ ហុងគាត់មកនៅហ្នឹងដែរ ហើយប៉ុនអាត្មាជាទំនាក់ទំនង យើងហៅថាទំនាក់ទំនង ។

ដានី ៖ ករុណា!

សៅ ៖ អាត្មាវាទំនាក់ទំនង វាមែនទែនទៅវាចូលទំនាក់ទំនងយោធា យោធាថៃនឹងយោធាខ្មែរក្រហមហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ ពរ!ហើយនឹងសម្រួលសភាពការណ៍អី ។

ដានី ៖ យើងទាក់ទងខាងថៃ ខាងនេះហ្នឹង យើងទាក់ទងយ៉ាងម៉េច ដូរស់ប្តូរ ឬក៏គ្រាន់តែថាប្រជាជនចេញចូល ឬមានដូចជាសំភារៈភស្តុភារអីផ្សេងទៀត?

សៅ ៖ គឺដោយខ្សែខាងដឹកជញ្ជូនម៉ោហ្នឹងគឺយោធាថៃហើយ ក៏ប៉ុនក្រៅឯកសណ្ឋាន ។

ដានី ៖	ក្រៅឯកសណ្ឋានទេ?

សៅ ៖	ហ្នឹងហើយ អាហ្នឹងគេដឹកជញ្ជូនទេ យើងបើកច្រក សំខាន់ថាយើងនៅត្រង់ណាទេ ត្រូវមានគណៈទាក់ទង ដូចជារូបអាត្មាហ្នឹងសម្រាប់ដោះស្រាយសភាពការណ៍ហេតុកើតឡើង យើងត្រូវទំនាក់ទំនងមានអីខ្លះ ឥឡូវយើងត្រូវពឹងអីខ្លះ ឬក៏យើងមានរឿងអីខ្លះ ឬក៏គេត្រូវពឹងអីយើងខ្លះ ប៉ុណ្ណឹងឯង ។

ដានី ៖	ចុះកាលហ្នឹង អៀង សារី គាត់នៅម៉ាឡៃឬក៏នៅណា ដល់ពេលបែក?

សៅ ៖	គាត់នៅជរ២៥ ឬក៏គេហៅថា៨៦ គាត់នៅវត្តតណាលនុជន ស្រុកវត្តតណាលនុជនថៃ ។

ដានី ៖	ករុណា!

សៅ ៖	គាត់ជួលដី គឺជួលដីគេមកកន្លែងនៅស្រុកវត្តតណាលនុជនខេត្តស្រះកែវយើងសព្វថ្ងៃ ។

ដានី ៖	ករុណា!

សៅ ៖	ឆ្នាំ១៩៨៦ហ្នឹងជួលសម្រាប់ៗប្រជុំ ។

ដានី ៖	សម្រាប់ប្រជុំ?

សៅ ៖	ហ្នឹងហើយប្រមូលពីនេះនោះអីហ្នឹងទៅប្រជុំហ្នឹង កម្មាភិបាលថ្នាក់វរៈអីហ្នឹង ។

ដានី ៖	ករុណា!

សៅ ៖	តែគាត់នៅមែនទែនជរ២៥នោះ ប៉ៃតុងនោះ ។

ដានី ៖	នៅណាប៉ៃតុង?

សៅ ៖	ដីថៃនោះ ខាងខ្មែរយើងហៅថាកន្លែងជរ២៥ហ្នឹង បើនៅថៃវិញគេហៅថា ប៉ៃតុង ។ ប៉ៃតុងហ្នឹងភូមិប៉ៃតុង ស្រុកគង់ណាំរ៉ន ខេត្តចាន់ធបូរី ។

ដានី ៖	ករុណា!

សៅ ៖	ប៉ុនវានៅជាប់ស្រះកែវ ។

ដានី ៖	ករុណា!ប៉ុនដឹប៉ុល ពតគាត់នៅភ្នំប្រាក់វិញ?

សៅ ៖	ប៉ុល ពត កាលហ្នឹងគាត់ម៉ោនេះទេ កាលហ្នឹងគាត់នៅអូរទារនោះ ប៉ុននៅជរ៨៨នោះ ជរ៨៨អីហើយបានគាត់ម៉ោនៅនេះ ហ្នឹង៨៨ហើយដល់ពេលខាង៨៩នេះ អេស៎! ៩០ គាត់នៅតាស៎ ។

ដានី ៖	គាត់នៅ?

សៅ ៖ ហ្នឹងហើយ!ទាល់តែពេលខាងTBនេះ ខាងប៉ុព្វនេះ ដោយសារបោះឆ្នោតហើយ អត់ចូលបោះឆ្នោតគេហ្នឹង គាត់ទៅវៃភ្នំប្រាក់ហ្នឹង បាន ប៉ុល ពតរើទៅនៅអន្លង់វែង ។ពរចេញពីហ្នឹងហើយ ព្រោះដឹងដែនការថាវៃ ។

ដានី ៖ករុណា!

សៅ ៖ ពរ!ខាងប៉ុព្វវៃ ។

ដានី ៖ ចុះបើ នួន ជា ខៀវ សំផនអីគាត់នៅណាកាលហ្នឹង?

សៅ ៖ ខៀវ សំផនកាល ព្រោះតាៗហ្នឹងគាត់កាលដើមឡើយហ្នឹងនៅជុំគ្នាឯនោះ ។

ដានី ៖ នៅជុំគ្នា?

សៅ ៖ ប៉ុន្តែ បើថាខៀវ សំផន អីគាត់អត់ទៀងទេ ព្រោះគាត់ក្តាប់ការបរទេសនោះ ។

ដានី ៖ករុណា!

សៅ ៖ ជាមួយអៀង សារីនោះគាត់អត់ទៀងទេ ប៉ុន្តែអាកន្ទែងជូនកាលទៅនៅ ជូនកាលទៅម៉ោមន្ទីរទឹកធ្លាក់ហ្នឹងទៅ មានការងារត្រូវហ្នឹងទទួលភ្ញៀវត្រង់ហ្នឹងទៅ ជូនកាលទៅនៅដរ២៥ថានៅដីថៃនោះណា ។

ដានី ៖ករុណា!

សៅ ៖ ហ្នឹងជូនកាលទៅជិត ប៉ុល ពត នោះទៅៗអូរទារទៅ ។

ដានី ៖ករុណា!

សៅ ៖ ហ្នឹងជូនកាលគាត់ម៉ោម៉ាឡៃម៉ោ ទទួលសារតាំងអីនៅម៉ាឡៃនេះ ។

ដានី ៖ករុណា!

សៅ ៖ ព្រោះកាលហ្នឹងអសនះកម្ពុជាប្រជាធិបតេយ្យនៅឡើយ ។

ដានី ៖ករុណា!

សៅ ៖ ហ្នឹងហើយយើងមិនទាន់បានច្របាច់បញ្ចូលទៅជាចតុភាគី ទៅជាត្រីភាគីណា ដូច្នេះទទួលសារតាំងនៅម៉ាឡៃទៅ ។

ដានី ៖ករុណា!

សៅ ៖ ប៉ុន្តែ ប៉ុល ពត គាត់កំរមានវត្តមានណាស់ កំរណាស់មានតែតា នួន ជា ខៀវសំផន តាអៀង សារី តានួន ជា គាត់ប្រលូកខាងអប់រំនយោបាយ ។

ដានី ៖ករុណា!

សៅ ៖ ហ្នឹង ហើយឯខាងលោកតា អៀង សារីគាត់ខាងការទូតផង ហ្នឹងសេដ្ឋកិច្ច ទទួលសេដ្ឋកិច្ច ។

ដានី ៖ ខាងអ្នកទទួលសេដ្ឋកិច្ច?

សៅ ៖ ហ្នឹងហើយ ឯអ៊ំខៀវ សំផន គាត់មែនទែនទៅគាត់ជាប្រមុខ ។

ដានី ៖ករុណា!

សៅ ៖ ប្រមុខហ្នឹងប៉ុនក្រោមការចាត់ចែងរបស់ ប៉ុល ពតទាំងអស់ហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹង ហើយដោយឡែកបើខាងយោធាវិញ ឯកឧត្តម សុន សេននោះ សុន សេនហ្នឹងទៅ ហើយតាម៉ុកហ្នឹងហើយ ។

ដានី ៖ កាលហ្នឹងដូច អៀង សារី គាត់មានផ្ទះមួយនៅម៉ាឡៃ?

សៅ ៖ មានតាស៎!

ដានី ៖ គាត់ម៉ោនៅហ្នឹងជាប់លាប់ដែរ អីយ៉ាងម៉េច?

សៅ ៖ ម៉ោជានិច្ចជាកាល គាត់ល្អែងតែមានសភាពការណ៍ល្អគាត់ម៉ោនៅហ្នឹងឯង នៅខែៗអត់រវល់បើអត់រវល់គាត់នៅខែលៗ ។

ដានី ៖ ករុណា! ចុះមួយទៀតព្រះអង្គដែលជួប ហង់ ពិនហ្នឹងឬអត់ កាលពីព្រះអង្គនៅទាក់ ទង់?

សៅ ៖ ណែ៎!កាលហ្នឹងអាត្មាឯងជាអ្នកទទួល ។

ដានី ៖ ជាអ្នកទទួល?

សៅ ៖ ព្រោះគាត់ សូរ ហុង មិនដឹងប្រើពីណា ប្រាប់ថាកម្លាំងអ៊ំៗមិនមានតែតាពិនហ្នឹងណា៎ មានអើមីង នៅអន្លង់វែងសព្វថ្ងៃ ប្រពន្ធតាជូ ប្រពន្ធអ្នកទូតអីនោះណា៎!មីង មឿន ម៉ោជាមួយមីងមឿន នៅការ៉ាសសាំងអន្លង់វែងនោះណា៎ ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ ម៉ោមួយក្រុមហ្នឹងមាន ហើយនឹងមានគាត់ហ្នឹងផង តាពិនហ្នឹងផង ។

ដានី ៖ តាពិន ប្រពន្ធគាត់ មីងរុំហ្នឹង?

សៅ ៖ ហ្នឹងហើយ ហើយមាននារីមីងៗហ្នឹងប៉ុន្មាននាក់ទៀត ហ្នឹងមៅហ្នឹងណា៎ ហើយគាត់ម៉ោហ្នឹងក៏នៅតាមភូមិអញ្ចឹងទៅ ព្រោះវាតំបន់នេះមិនមានការបះទង្គិចអីហើយ ។

ដានី ៖ កាលហ្នឹង សូរ ហុង គាត់ប្រាប់ព្រះអង្គថាម៉េចខ្លះ?

សៅ ៖ អត់ ថាកម្លាំងម៉ោពីកោះកុង ។

ដានី ៖ កម្លាំងម៉ោពីកោះកុងកម្លាំងរបស់ពីណាគេ?

សៅ ៖ កម្លាំងគឺថារបស់អ៊ីគឺរបស់ ប៉ុល ពត ហ្នឹង ។

ដានី ៖ កម្លាំងរបស់ ប៉ុល ពត?

សៅ ៖ ហ្នឹង ហើយក៏បានដឹងតែប៉ុណ្ណឹង ហើយតាឌុចអីនេះជួបគ្នារាល់តែដងហ្នឹងគាត់នៅកងអី ព្រោះអាគ្នាខាងដឹកជញ្ជូនអីហាង កាលហ្នឹងយើងមានឡានប្រើប្រាស់ហើយ ឡានដឹកជញ្ជូនអីម៉ោ ហ្នឹងហើយខបត្ដូមកងទ័ព ដោះអីៗគឺអាគ្នាហ្នឹងជាអ្នកទទួលបន្ទុកខាង ហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹង ក្រោយពី១៩៨៦-៨៧ហ្នឹង មានឡានប្រែហើយ ឡានចិន ។

ដានី ៖ ចុះអ៊ើ!ព្រះអង្គដូចថា សូរ ហុង គាត់អ៊ើដូចថាផ្ដាំផ្ញើរមកព្រះអង្គថាឲ្យកម្លាំងរបស់អ៊ីៗ ម៉ោមានគាពិន យាយមឿនប្រពន្ធគាត់ ហើយយាយរីហ្នឹង កាលហ្នឹងឆ្នាំណាដែលគេបញ្ជូនម៉ោ បញ្ជូនគាពិនម៉ោ?

សៅ ៖ ដូច៨៧ បើមិន៨៧-៨៨ ។

ដានី ៖ បញ្ជូនម៉ោឲ្យនៅណាដំបូង?

សៅ ៖ ម៉ោនៅភ្នំប្រាក់ ។

ដានី ៖ ភ្នំប្រាក់?

សៅ ៖ ហ្នឹងហើយ ហើយបានឲ្យគាត់មកនៅតាមភូមិ ។

ដានី ៖ ឆ្នាំណាបានឲ្យម៉ោនៅតាមភូមិ?

សៅ ៖ ម៉ោនៅហ្នឹងបែបមិនបានយូរទេ ៣-៤ខែ ២-៣ខែ ក៏ម៉ោនៅភូមិបន្កលកុណៈជាមួយប្រជាជនតាមភូមិហ្នឹង ហើយមីងមឿនហ្នឹងគាត់មិនបានម៉ោបោះទីតាំងទេ គាត់មានតួនាទីចលនានយោបាយ ។

ដានី ៖ អ្នកនយោបាយ?

សៅ ៖ ពរ!ដោយខ្សែក ឌុច នេះគឺម៉ោ របៀបម៉ោជ្រក ម៉ោបោះទីតាំងនៅដូចជាប្រជាពលរដ្ឋយើងដូចគេដូចឯងអញ្ចឹង ។

ដានី ៖ កាលហ្នឹងខាងអ៊ីគាត់ចាត់ឲ្យម៉ោបោះទីតាំងនៅហ្នឹងឬក៏គាត់ម៉ោ?

សៅ ៖ អត់ទេ!សុទ្ធតែមាន អញ្ចេះគឺកាលហ្នឹងគឺប្រកាសៗទូទាំងជួរខ្មែរក្រហមហ្នឹង ឆ្នាំ១៩៨៨ ហ្នឹង ចុងឆ្នាំ៨៧ហ្នឹងបានប្រកាសហើយថាយើងគឺអស់ជំនួយហើយ សូម ម្ចាស់ការហ្នឹងគឺមានទឹកមានដីហើយ ដូច្នេះសូមប្រឹងប្រែងមាគ៌ាសេដ្ឋកិច្ចគ្រួសារ ហ្នឹង

ហើយមិនដឹងជាគាត់ហ្នឹងចាត់តាំងឲ្យម៉ោនៅប្តីតាឌុច ហ្នឹងគាត់ជ្រើសរើម៉ោដោយខ្លួនគាត់ទេ ប៉ុន្តែគ្រន់ថាអាត្មានេះជាអ្នកនាំគាត់ម៉ោដាក់ឡានទ្រុងចិនហ្នឹង ។

ដានី : នាំពីត្រឹមណាមកត្រឹមណា?

សៅ : នាំពីភ្នំប្រាក់ម៉ោ ។

ដានី : នាំពីភ្នំប្រាក់?

សៅ : ពរ!ជិះឡានហ្នឹង ដឹកគាត់ៗមកនៅផ្លូវនេះ គាត់ដាក់មៅ ព្រោះឡានហ្នឹងចេញចូល ព្រោះចេញចូលរាល់ថ្ងៃ ព្រោះកងទ័ពនៅតាមនេះវាច្រើន ជួនកាលដឹកនាំម៉ោ ទៅវិញដឹកស្រូវ កាលហ្នឹងទិញស្រូវនៅតាមភូមិ ត្រូវទៅវិញផង ។

ដានី : ចុះ អញ្ចឹងសួរ ហុង គាត់មានផ្ដាំផ្ញើរអីខាង?

សៅ : អត់!អត់មានដឹងអីទាំងអស់ នេះឌុចនេះបានឃើញមុខ គេថាតាឌុច បានភ្ញាក់ខ្លួនហើយអាត្មាហៅគាត់តែពូៗហ្នឹង ។

ដានី : ហៅតែពូ?

សៅ : ហ្នឹងហើយ ហៅតែពូ ចុះហៅដូចធម្មតាអញ្ចឹង វ័យប៉ុណ្ណឹងហើយអាត្មាកាលហ្នឹងហៅគាត់ពូ គ្រួសារគាត់ខ្មៅ ក្រញ៉ិប ។

ដានី : ខ្មៅក្រញ៉ិប?

សៅ : ហ្នឹងហើយ គាត់សើចអាញ៉ឹមអាញ៉ាមហ្នឹង ។

ដានី : ចុះព្រះអង្គអត់ដឹងប្រវត្តិគាត់?

សៅ : អត់!អត់ដឹងសោះ ។

ដានី : គាត់អត់ដែលមាននិយាយលេងជាមួយព្រះអង្គទេ?

សៅ : អត់! ហើយគាត់ខុះខាតអីហ្នឹង ផ្ញើរអីប្តីគាត់ធ្វើដំណើរពីហ្នឹងទៅភ្នំឆត្រវិញគាត់ដោយសារឡានអាត្មាទៅ ព្រោះអាត្មាកាលហ្នឹងអ្នកទទួលដឹកជញ្ជូននោះ ។

ដានី : ករុណា!

សៅ : ហ្នឹងហើយ ព្រោះដីយើងបានទូលាយហើយ ។

ដានី : អញ្ចឹងពេលដែលគាត់ម៉ោនៅដល់ផ្លូវហ្នឹងហើយ ក៏គាត់ខស្សាប់ទៅភ្នំឆត្រហ្នឹងវិញ ដែរ?

សៅ : យូរៗគាត់ទៅដែរ ប៉ុន្តែឃើញកន្ទះខែមាំខែអី ។

ដានី : តាឌុចហ៊ឹងគាត់ទៅ?

សៅ : ពរ!

ដានី ៖ ចុះប្រពន្ធគាត់អី?

សៅ ៖ ជួនកាលឃើញទៅដែរ ជួនកាលគាត់ទៅទិញឥវ៉ាន់អីព្រោះនៅហ្នឹងវាឡើងពីហ្នឹងទៅនេះ ទៅវាចុះព្រំដែនថៃនោះ សាត់ស្វាហ្សហ្នឹង ទៅទិញឥវ៉ាន់គាត់លក់អីៗរបស់គាត់អញ្ចឹង ទៅ ឬមួយក៏គាត់ទៅការងាររអីខាងផ្ទៃក្នុងរបស់គាត់យើងក៏មិនដឹង ។

ដានី ៖ ដូចថារបៀបគាត់លក់ដូរ កាលហ្នឹងគាត់ម៉ោនៅហ្នឹង ដូចគាត់មានដាំងគេ មានម៉ាស៊ីនស្រូវ មានលក់ដូរ?

សៅ ៖ ហ្នឹងឯង ព្រោះកាលហ្នឹង អាត្មាអីក៏មានដែរ ព្រោះគេឲ្យបែក ។

ដានី ៖ ឲ្យបែក?

សៅ ៖ ឲ្យបែកឧទាហរណ៍ថា ដូចអង្គភាពនេះត្រូវបានយកអី យកម៉ាស៊ីកិនស្រូវឬក៏យកគោយន្តយកអីទៅណាស់ ព្រោះវាត្រូវគោរិនលែងអង្គភាពហើយ ព្រោះអស់លែងមានជំនួយហើយ ។

ដា នី ៖ ហ្នឹងជារបស់អង្គការ មិនមែនជាលុយ?

សៅ ៖ លុយម៉ោពី ប៉ុល ពត ខ្លះ ហើយអាស្រ័យយើងនៅតាមអង្គភាពយើងរកស៊ីផ្ទាល់ខ្លួនខ្លះ ។

ដានី ៖ករុណា!

សៅ ៖ ហ្នឹងហើយ!

ដានី ៖ ចុះព្រះអង្គមានដឹងថាពេលហ្នឹង តាឌុច ហើយនឹងប្រពន្ធគាត់ ពេលឡើងទៅភ្នំឆត្រហ្នឹង គាត់មានដែលជួបអ៊ំដូចជាអ៊ំ ប៉ុល ពត អ៊ំ អៀង សារី?

សៅ ៖ ណែ៎ចេះ!អាត្មានៅៗខាងជើងភ្នំ ។

ដានី ៖ ករុណា!

សៅ ៖ ប្រហែលជា៨-៩០០ម៉ែត្រម៉ាគីឡូ ។

ដានី ៖ ករុណា!

សៅ ៖ ហើយអាកន្លែងភ្នំពើក ភ្នំហ្នឹងកន្លែងអ៊ំពតគាត់នៅជាមួយ សូរ ហុងហ្នឹងៗហ្នឹងហើយ គាត់ទៅឡានឈប់តែការសហ្នឹង គាត់ទិញអីគាត់មិនដែលសម្រាកផ្ទះអាត្មាទេ គាត់មកសម្រាកតែជាមួយតាសូរ ហុងហ្នឹង ហើយតាសូរ ហុង ហ្នឹងផ្ទះប៉ុល ពត ហ្នឹង បានន័យថាគាត់ចេញចូលកន្លែងហ្នឹងជាធម្មតា ។

ដានី ៖ អញ្ចឹងតាឌុចហ្នឹងគាត់ទៅសម្រាកកន្លែងផ្ទះ សូរ ហុង?

សៅ :	ពរ!ហ្នឹងហើយ គាត់ចូលក្នុងបរិវេណហ្នឹងៗ ។

ដានី :	គាត់ខស្សារាហ៍ទៅដែរអញ្ចឹង?

សៅ :	ទៅយូរៗឃើញមួយដឹងដែរ ប៉ុន្តែគាត់រស់នៅសាមញ្ញណាស់អត់មានអ្នកណាដឹងទេ ។

ដានី :	ករុណា!

សៅ :	ប្រហែលអាត្មានៅជិតិតសូរ ហុង ហើយហ្នឹងចុះឃើញ ពួកយាយមឿន យាយអីមៅ ហើយដូចអត់ យាយមឿន ដឹងដែរ ប៉ុនពេជ្រជាងហើយហ្នឹង ធ្លាប់ទៅធ្វើទូតនៅចិន នៅអីដឹងប្រវត្តិ និយាយសាធូម៉ោម៉ង ម៉ោមីនសែអី ប៊ុនពេជ្រប៊ុនអី ហើយយើង ធ្លាប់ធ្វើការ ហើយធ្លាប់ធ្វើការ ឌុច អត់ចាប់អារម្មណ៍សោះ ។

ដានី :	ករុណា!

សៅ :	អត់ៗ!អាត្មាអត់នឹកថា ជាមានតួនាទីអី ស្មានតែអ្នកកម្លាំងមន្ទីរអ្នកគស៊ូចាស់អ ធម្មតា ។

ដានី :	ករុណា!

សៅ :	ក្រៅពីហ្នឹងដឹង ចូលម៉ោដឹង ចាន់ យូរ៉ាន់អីម៉ោទទួលទានអាហារពេលបាយជាមួយ អាត្មាអីហ្នឹង ហ្នឹងហើយទទួលឲ្យតែភ្ញៀវម៉ោពីណា ភ្ញៀវថ្នាក់ដឹកនាំក្នុងជួរខ្មែរក្រហម ហ្នឹងឬក៏អន្តរជាតិ ឲ្យតែម៉ោច្រកហ្នឹងគឺអាត្មាជាអ្នករត់ការណ៍ ជាអ្នកបំរើការ ។

ដានី :	ករុណា!

សៅ :	ហ្នឹងហើយ!ប៉ុនដោយឡែកគាត់អត់ៗដឹងទេ ធ្លាប់និយាយលេងជាមួយគាត់នៅភ្នំឆត្រ ហ្នឹងក្តី ហើយនៅផ្កាំ ហើយធម្មតា អត់ៗ ។

ដានី :	អត់ដឹងថាឌុច គាត់មានតួនាទីអី ជាប្រធានគុកទួលស្លែងអី?

សៅ :	អត់ៗ ។

ដានី :	ព្រះអង្គឥឡូវហ្នឹងមានខាងតុលាការគេជំនុំជំរះឌុចអីអញ្ចឹង ដោយសារព្រះអង្គ ធ្លាប់ស្គាល់គាត់ពីមុនម៉ោ អញ្ចឹងព្រះអង្គមានអារម្មណ៍ថាម៉េចដែរ ដល់ពេលដឹងរឿងថាគាត់ ប្រធានគុកទួលស្លែង?

សៅ :	និយាយសាធូអី ដល់ភ្ញាក់ៗតែដឹងដល់ថ្នាក់ដឹកនាំកំពូលធ្លាប់ជួបគាត់អី អត់ភ្ញាក់ផ្អើរ ទេ ។

ដានី :	ករុណា!

សៅ :	និយាយសាធូទៅដូចថា លោកអៀង សារី លោកនួន ជា ហើយគាត់ហ្នឹងចេះភាសា ថៃទៀតផង កាលណាភាសាថៃអាត្មាអីមិនសូវចេះសួរគាត់ហើយ ។

ដានី :	សួរពីណាគេ?

សៅ : សួរនួន ជា គាត់ចេះច្បាស់ណាស់ គាត់ចេះច្រើនភាសាណាស់ ។

ដានី : ករុណា!

សៅ : ហ្នឹងហើយ! ហើយអត់ភ្ញាក់ផ្អើរទេ ទោះបីជាគ្រួសារ ខៀវ សំផនក៏ធ្លាប់នៅជាមួយ គាត់នៅផ្ទះក្បែរៗគ្នា ។

ដានី : យាយរិនហ្នឹង?

សៅ : ហ្នឹងហើយ យាយរិនហ្នឹង កូនគាត់ហ្នឹងអាគ្រូច អាអី ហ្នឹងអត់ទោះបីជាពូគាត់ឈឺ ឬក៏ពូថាគេត្រូវហៅថា ជាប់ចោទអញ្ចឹង អត់អី តែដល់ខុចនេះវាភ្ញាក់ផ្អើរត្រង់ថា ជុំម៉ោនៅក្បែរគ្នា អត់ដឹងប្រវត្តិចេះមួយៗអត់ដឹង វាប្រភេទហ្នឹង ។

ដានី : ករុណា!

សៅ : ពរ!

ដានី : ហើយមួយទៀត ព្រះអង្គតាមទស្សនៈរបស់ព្រះអង្គផ្ទាល់ ព្រះអង្គយល់ឃើញថាតុលាការដែលគេបង្កើតឡើងដើម្បីជំនុំជំរះទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នឹងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលកើតឡើងពីជំនាន់៧៥ដល់៧៩ហ្នឹងព្រះអង្គយល់ឃើញយ៉ាងម៉េចដែរ បើតាមទស្សនៈរបស់ព្រះអង្គផ្ទាល់?

សៅ : ណែ!សម្រាប់ពេលនេះណ៎ អាត្មាបួសហើយ មិនគួរនឹងចំលើយទេ ។

ដានី : ករុណា!

សៅ : តែបើញោមត្រូវការសួរហើយ!

ដានី : ករុណា!

សៅ : អាត្មាដោយឡែក ថាក្រៅព្រះធម៌ទៅចុះ!

ដានី : ករុណា!

សៅ : ការពិតអាត្មាបួសហើយ មិនគួរហៅថាបញ្ចេញទស្សនៈអីឬគួរមិនគួរ សមឬមិនសម ទេ!

ដានី : ករុណា!

សៅ : តែញោមគាត់មកពីស្រុកឆ្ងាយហើយ គឺថាជម្រាបទស្សនៈបន្តិចទៅចុះ ការពិតទៅយើងឆ្លើយបានអ៊ីៗ តែឲ្យបញ្ចេញទស្សនៈដល់យើងជាបួសជាព្រះសង្ឃអញ្ចឹងហើយ ហ្នឹងដល់បញ្ចេញទស្សនៈអញ្ចឹងទៅវាប៉ះពាល់ដល់សិក្ខាបទផ្ទាល់ខ្លួនដែរ តែដោយឃើញមានមេត្តានុះណ៎!ញោមគាត់ម៉ោឆ្ងាយហើយ ចង់បានចំលើយលោកពីអតីតទេ មិនមែនពីចប្បុប្បន្នកាលនេះទេ ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹង ដោយសារអាត្មាក៏រស់នៅក្នុងសង្គមហ្នឹង ដូចជាគេឯងដែរហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ អាត្មាថាគ្រាន់តែមានបាយ មិនដែលបបរមែនក៏ប៉ុន្តែ ធ្វើការនោះ ហើយនឹងរូបភាពនឹងវាៗចុកចាប់ណាស់ទៅហើយ ។

ដានី ៖ ករុណា!

សៅ ៖ ហើយចុះល្មមអ្នកដ៏ទៃទៀត ដែលគាត់មិនបានបរិភោគបាយរឹងហ្នឹង តើវាយ៉ាងណានោះណា៎!

ដានី ៖ ករុណា!

សៅ ៖ ឯការកាត់ទោសនេះ បើអាត្មាៗថាកាត់ទោសខុច គ្រាន់តែបុគ្គលទី៤-ទី៥ទេ ។

ដានី ៖ ករុណាៗ!

សៅ ៖ ហ្នឹង!ដាក់ទោសគាត់ឲ្យធ្ងន់ជាងនេះក៏មិនគួរដែរ ។

ដានី ៖ ករុណា!

សៅ ៖ តែបើនេះសម្រាប់អាត្មាផ្ទាល់ណា៎ តែសិនជាអត់សោះក៏មិនគួរដែរ ។

ដានី ៖ ករុណា!

សៅ ៖ ព្រោះគាត់ពេលនោះមិនថាតែខុច ឬក៏អាត្មាទេ ឬក៏បុគ្គលណាទេ គឺបញ្ហាអត់មានក្រដាសស្នាមទេ គឺម៉ាមាត់នេះអីស្មើនឹងស្លាប់ស្មើរស់ ។

ដានី ៖ ករុណាៗ!

សៅ ៖ ពរ!

ដានី ៖ ចុះចំពោះករណី អ៊ំៗផ្សេងទៀតដែលថា ព្រះអង្គធ្លាប់នៅជាមួយគាត់ មានមនោសញ្ចេតនាជាមួយគាត់ច្រើនដូចជា អ៊ំអៀង សារី អ៊ំ ខៀវ សំផន នួន ជា ដូច ថា ព្រះអង្គធ្លាប់រស់នៅជាមួយគាត់កាលពីអតីតកាលអញ្ចឹង ដូចថាធ្លាប់មានស្គាល់គ្នាមានមនោសញ្ចេតនាជាមួយគ្នាអញ្ចឹង ដល់ពេលឥឡូវគាត់ត្រូវបានតុលាការគេចាប់ គាត់ឃុំឃាំងគាត់ជាជនជាប់ចោទ នឹងត្រូវគេកាត់ទោសឆាប់ៗនេះ ហើយព្រះអង្គយល់ឃើញយ៉ាងម៉េចដែរ ?

សៅ ៖ ចំពោះរឿងនេះ អាត្មានៅក្នុងផ្លូវខែរក្រហមរហូតម៉ោណា៎! ។

ដានី ៖ ករុណា!

សៅ ៖ ក៏មិនកាន់ដើងទេ!

ដានី ៖ ករុណា!

សៅ ៖ ព្រោះកំហុសទាំងនេះ មិនថាខ្ទាំងពីណាឬក៏មហិច្ឆតាពីបរទេសណាក៏ដោយ ។

ដានី ៖ ករុណា!

សៅ ៖ ក៏ពួកគាត់ថ្នាក់ដឹកនាំនេះត្រូវតែទទួលខុសត្រូវ ។

ដានី ៖ ករុណា ៗ!

សៅ ៖ ព្រោះម៉េចបានអាត្មាថាយ៉ាងហ្នឹងព្រោះ បានន័យថា ខណៈនោះគឺគាត់ជាអ្នកទទួលខុសត្រូវវាសនាជីវិតខ្មែរទាំងអស់ហើយ ហើយការខុសឆ្គងរបស់គាត់គឺមិនមែនថាគាត់មិនដឹងទេ អាត្មាជឿៗថាគាត់មិនដឹងទេ ដូច្នេះអាត្មាសរុបថា អ៊ឹប៉ុល ពត ជាមនុស្សមួយខ្លាចបំផុតមើលអ្នកណាក៏ជាសត្រូវទាំងអស់ ។

ដានី ៖ ករុណា!

សៅ ៖ មើលបុគ្គលណាក៏ជាសត្រូវទាំងអស់ ។

ដានី ៖ ករុណា!

សៅ ៖ នេះតែបើលោក អៀង សារី គាត់មនុស្សទាន់សម័យ វត្តវ៉ាអីគាត់ឲ្យបើក នេះកាលនៅម៉ាឡៃនៅអីនេះ សុខ ភាពអីបបួលគ្នាធ្វើវត្ត ពតម៉ោឲ្យនាយកន សុន សេន រើវត្តខ្ទិច អាជិតដាច់ខ្លួនហើយនេះហ្នឹង ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ!ហ្នឹងដែលត្រូវគ្នាជិតបោះឆ្នោតហើយហ្នឹង បបួលគ្នាធ្វើវត្តធ្វើអីនោះណា៎ គាត់មនុស្សទាន់សម័យ ។

ដានី ៖ ករុណា!

សៅ ៖ បានជាដឹងថាគាត់ជាមនុស្សទាន់សម័យ អាត្មាធ្លាប់ឮភាសាគាត់ ឮភាសាអៀង វុធ ដែរកាលពីរំដោះ១៩៧៩ហើយ លោក អៀង សារី គាត់ការទូតនោះ ។

ដានី ៖ ករុណា!

សៅ ៖ គាត់ដឹងប្រាក់ ក្រដាសប្រាក់ពីចិនម៉ោហ្នឹង ហើយគាត់និយាយ គាត់និយាយផ្ទាល់ គាត់ថាគេធំជាងឯង ។

ដានី ៖ ករុណា!

សៅ ៖ គេថា ត្របោមិនឈឺកុំយកឈើចាក់ ដូច្នេះគាត់បានន័យថាគាត់ជាអ្នកទាន់សម័យ ។

ដានី ៖ ករុណា!

សៅ ៖ ហ្នឹងហើយ!មិនមែននេះទេ តែដោយមិនបាច់អីទេ តែត្រង់ថាសំនួរមិញហ្នឹងគឺថាអាត្មាថាគួរតែពួកគាត់ជាអ្នកទទួលខុសត្រូវ ។

ដានី ៖ ព្រះអង្គនេះគ្រួសារព្រះអង្គគាត់ឈ្មោះអីដែរអតីត?

សៅ ៖ ញោមនេះ ញោមក្រោយ ។

ដានី ៖ ញោមក្រោយ អញ្ចឹងញោមមុនឈ្មោះអីទៅ?

សៅ ៖ ញោមមុនឈ្មោះ យ៉ន ភា ។

ដានី ៖ យ៉ន ភា?

សៅ ៖ ពរ!ហ្នឹង យ៉ន ភាហ្នឹងក៏នៅជាមួយមីង៉រិនមីង៉អីគ្រួសារលោក ខៀវ សំផនហើយ ហ្នឹង ។

ដានី ៖ អ្ហូ!ហ្នឹងៗញោម?

សៅ ៖ ញោម ដើម បានគ្នានៅលើខ្នងភ្នំហ្នឹង ។

ដានី ៖ ឆ្នាំណាហ្នឹងរៀប?

សៅ ៖ ឆ្នាំ៨០ ។

ដានី ៖ ព្រះអង្គមានកូនចៅប៉ុន្មានកាលហ្នឹង?

សៅ ៖ កាលហ្នឹងបាន៤នាក់ ។

ដានី ៖ បានកូនចៅ៤នាក់?

សៅ ៖ ពរ! ក្រោយយើងសង្គ្រាមហើយ ក្រោយ៨៧-៨៨ក៏បែកបាក់គ្នា ។

ដានី ៖ ករុណា!ដល់អញ្ចឹងគាត់ទៅរស់នៅណាទៅ?

សៅ ៖ គាត់រស់នៅអើភូមិព្រីង នៅស្រុកស្វាយលើ ខេត្តសៀមរាប ។

ដានី ៖ ភូមិព្រីង?

សៅ ៖ ភូមិពរីង ។

ដានី ៖ ឃុំក្បាលអរ?

សៅ ៖ ឃុំអីទេ!ឃុំក្បាលអរហ្នឹងឯង មុំម៉ាជួរហ្នឹង ។

ដានី ៖ គាត់នៅជាមួយអើ?

សៅ ៖ ជាមួយគ្រួសារក្រោយគាត់ ។

ដានី ៖ អ្ហូ!ជាមួយគ្រួសារក្រោយ?

សៅ ៖ ហ្នឹងគាត់ក៏បានគ្រួសារ អាត្មាក៏បានញោមក្រោយនេះដែរ ។

ដានី ៖ តែគាត់ អតីតភាពរបស់គាត់ៗនៅជាមួយ?

សៅ ៖ គាត់នៅសម័យ៣ឆ្នាំហ្នឹង គាត់ទៅនៅហ្នឹងមន្ទីរក្រសួងការបរទេសហ្នឹងម៉ង នៅភ្នំពេញហ្នឹងម៉ង នៅជាមួយខាងតាៗយាយៗហ្នឹង ក្រោយពី៧៩ហើយគេត្រូវរើសគាត់ ហើយគាត់ក្រោយម៉ោ គាត់ម៉ោនៅប្រចាំសៀមរាប កន្លែងទទួលភ្ញៀវសៀមរាប នៅជាគេថានារីទទួលភ្ញៀវ ។

ដានី ៖ ករុណា!

សៅ ៖ នៅកន្លែងទទួលភ្ញៀវ ។

ដានី ៖ ករុណា! គាត់អ្នកស្រុកកំណើតនៅណា?

សៅ ៖ គាត់អ្នកស្រុកនៅពរីងហ្នឹងម៉ង ។

ដានី ៖ នៅពរីងហ្នឹងម៉ងស្រុកកំណើតគាត់?

សៅ ៖ ពរ!ដូចលាយក្ងួយផងមិនដឹងទេ គាត់ក្ងួយ ។

ដានី ៖ អញ្ចឹងកាលជំនាន់ហ្នឹង គាត់នៅក្រសួងការបរទេស មិនមែនមន្ទីរ៨៧០ទេ?

សៅ ៖ ណែ៎!គាត់នៅក្រសួងការបរទេស ប៉ុន្តែនៅផ្នែកខាងសៀមរាប ។

ដានី ៖ ករុណា!

សៅ ៖ ហើយអាត្មាៗបណ្តេញគាត់ហ្នឹង កាលហ្នឹងគាត់នៅជាមួយ មីងរិន ហ្នឹង គ្រូសារអ៊ំ ខៀវសំផន ហ្នឹង ឈ្មោះគាត់ហៅអ៊ំ ហែម ហ្នឹង ហើយអាត្មាលោក ជាមនោះកាលហ្នឹងគាត់នៅមេក្រុម បងជាម គាត់ចូលចិត្តសារាយណាស់ បងជាម ហើយ និងមីងលី គ្រូសារគាត់ គាត់ហ្នឹងនៅមន្ទីរហ្នឹង គាត់ប្រធានទាំង មីងរិន អីទៀតប្រធានទាំងពួកអាត្មាទៀត ហើយឲ្យគាត់ដណ្តឹង១សារ ២សារ ៣សារ បានគេយកហើយកាលហ្នឹងការពកូ ប៉ែតជាងទៅហើយនៅតែការគូៗទៀត បបរសណ្តែក១ឆ្នាំងកូនឆ្នាំងតូចហើយ មីងរិន ហ្នឹងឯងប្រធាន ដូចថាមហា ហើយ មីងឈឿន គ្រូសារសូគ្រហំ ហើយ មីងហុន មួយទៀតនៅម៉ាខ្លៃ ។

ដានី ៖ ហុន គាត់ធ្វើអីគេ?

សៅ ៖ មីងហុន គាត់ហ្នឹងគឺអីចេះ គ្រូសារគាត់ឈ្មោះស៊្លី កងពលមកប្រចាំនេះសំរោង ឧត្តរមានជ័យ ត្រូវ តាយន បាញ់ស្លាប់ ខ្ញុំមួយសារហ្នឹងវិវិណាស់ ។

ដានី ៖ ឈ្មោះ ដុន ហ្នឹងមែន?

សៅ ៖ មិនមែនទេ ឈ្មោះ សឿន មីងហុន ហ្នឹង ដល់គាត់មេម៉ាយកំព្រាអីចឹងក៏ជាប់ជាមួយយាយៗតាមប្រវត្តិ ។

ដានី ៖ នៅកូនព្រះអង្គ៤នាក់មុននៅជួយគ្រួសារ?

សៅ ៖ មួយពៅស្លាប់គ្រួនឈាមហ្នឹងទេ នៅ៣ ហើយមួយមកលេងនេះ អាយុ២៨ហើយ កើត១៩៨២ ។

ដានី ៖ គ្រួសារព្រះអង្គក្រោយគាត់ឈ្មោះអីដែរ?

សៅ ៖ គាត់ឈ្មោះ វ៉ាន់ សុធា ញោមផ្ទះ៤ពីនេះទៅ ។

ដានី ៖ នៅសម្ភាសន៍ហ្នឹងដែរ?

សៅ ៖ នៅសម្ភាសន៍ហ្នឹង ។

ដានី ៖ ដល់គ្រួសារក្រោយមានកូនចៅទៀតដែរ?

សៅ ៖ ៣ នាងក្រោយគេក៏១៨ហើយ ។

ដានី ៖ ធំៗអស់ដែរ ។

សៅ ៖ បងនោះ១៨ហើយ រៀន១២ហើយឆ្នាំនេះ ១២ពីរនាក់ ។

ដានី ៖ ចុះញោមក្រោយនេះគាត់រៀបការនៅណាដែរ?

សៅ ៖ នៅភូមិហ្នឹងតែម្តង ។

ដានី ៖ គាត់អ្នកភូមិនៅហ្នឹង?

សៅ ៖ អ្នកភូមិហ្នឹង កំណើតហ្នឹង ។

ដានី ៖ ប៉ុន្តែគាត់មានទៅខាង?

សៅ ៖ អត់ទេ កាលហ្នឹងយើងឆ្នាំកៅជាង វាតំបន់នេះជាតំបន់ខ្មែរក្រហម តំបន់ប៉ាវ៉ា ។

ដានី ៖ ករុណាអរគុណព្រះអង្គច្រើន ។

សៅ ៖ អញ្ជើញចុះ ចាំអី អីយ៉ាងណាសុំអធ្យាស្រ័យផងចុះ អត្មាក៏មិនបានរកទឹកទទួលទេ ។

**ចប់**